# កិច្ចសន្យាជួលបឹងកក់
## សំនួរមួយចំនួនសំរាប់ការពិភាក្សា

## ១. សេចក្ដីផ្ដើម

ផែនការអភិវឌ្ឍន៍ក្នុងកិច្ចព្រមព្រៀងជួលបឹងកក់ត្រូវបានដាក់ជាចំណងជើងធំៗចុះផ្សាយក្នុងអត្ថបទ សារព័ត៌មានជាច្រើននាពេលថ្មីៗនេះ ហើយត្រូវបានគេដឹងគ្រប់ៗគ្នាថាគំរោងនេះមានផលប៉ះពាល់យ៉ាងខ្លាំង ទៅលើជីវភាពរស់នៅរបស់ប្រជាជនរាប់ពាន់គ្រួសារដែលរស់នៅក្នុងតំបន់នេះ។ កង្វះខាតព័ត៌មានពីស្ថានភាពបច្ចុប្បន្នស្ដីពីផែនការអភិវឌ្ឍន៍ ដែលបានស្នើឡើងនេះបានធ្វើអោយមានការលំបាក ក្នុងការពិភាក្សារវាងភាគីពាក់ព័ន្ធនានាដូចជាៈ សហគមន៍ អាជ្ញាធរ ក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយសហគមន៍។ ដោយមានព័ត៌មានតិចតួចស្ដីពីកិច្ចសន្យា ជួលនេះហើយជាហេតុនាំអោយមានការចោទជាសំណួរមួយចំនួនអំពីបែបបទ ដំណើរការ និងផលប៉ះពាល់ដែលបណ្ដាលមកពីការ អភិវឌ្ឍន៍នេះ។

អត្ថបទនេះមិនមែនជាការសិក្សា និងការវិភាគស៊ីជំរៅនោះទេ ប៉ុន្ដែគឺជាការពិនិត្យមើលជារួមលើបញ្ហា និងកង្វល់ទាំងឡាយសំរាប់បន្តការពិភាក្សាដូចជាៈ

- តើមានផែនការអ្វីខ្លះសំរាប់អភិវឌ្ឍតំបន់ជួលនេះ ហើយអ្វីជាគោលបំណងច្បាស់លាស់នោះ?
- ដោយហេតុថាបឹងកក់គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ហើយកិច្ចសន្យានេះមិនស្របនឹងមាត្រាទី ១៥ ១៦ និង ១៨ នៃច្បាប់ភូមិបាល តើអ្វីទៅជាចម្លាន្តរូបផ្លូវច្បាប់សំរាប់កិច្ចសន្យាជួលនេះ?
- ដោយគិតពីផលប៉ះពាល់ពហុវិស័យនៃគំរោងចាក់ដីបំពេញបឹងនេះ ចាំបាច់ត្រូវធ្វើការវាយតំលៃពីផលប៉ះពាល់បរិស្ថានដើម្បីយល់ដឹងច្បាស់លាស់ពីផលប៉ះពាល់ដែលបណ្ដាលមកពីគំរោងអភិវឌ្ឍន៍។
- តើនឹងមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្រុងភ្នំពេញនៅពេលណា និងដោយរបៀបណា?
- តើមានគោលនយោបាយរុះរើការតាំងទីលំនៅថ្មីយ៉ាងដូចម្ដេច ពាក់ព័ន្ធនឹងការផ្ដល់សំណង ដំណើរការការរៀបចំហិរញ្ញវត្ថុ និងការពិគ្រោះយោបល់ជាមួយគ្រួសារ និងអាជីវកម្មដែលរងការប៉ះពាល់ ?

ដោយហេតុថាមានបញ្ហា និងក្ដីកង្វល់ជាច្រើននោះ អត្ថបទនេះបញ្ចប់ដោយផ្ដល់នូវជំរើសថ្មីមួយដែលមាន ការគាំទ្រដល់អ្នកក្រចំពោះកិច្ចសន្យាជួលទៅអោយវិស័យឯកជន ដែលក្នុងនោះសាលាក្រុងភ្នំពេញ នឹងទទួលបានផលចំណេញទាំងនយោបាយ និងហិរញ្ញវត្ថុ ហើយសហគមន៍មូលដ្ឋានត្រូវបានផ្ដល់អំណាច និងទទួលបានសន្ដិសុខ កម្មសិទ្ធិដីធ្លី មិនតែប៉ុណ្ណោះ ថែមទាំងមិនមានផលប៉ះពាល់ដល់បរិស្ថានទៀតផង ដោយសារមិនមានការចាក់បំពេញ ដីទៅក្នុងបឹងនេះ។

## ២. ប្រវត្តិ

បឹងកក់មានទីតាំងស្ថិតនៅក្នុងខ័ណ្ឌដូនពេញ និងខ័ណ្ឌទួលគោក ក្រុងភ្នំពេញ។ បឹងនេះមានទំហំ ៩០ ហិកតា ព័ទ្ធជុំវិញដោយលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ។ សកម្មភាពអាជីវកម្មមានដូចជាការប្រកបមុខរបរខ្នាតតូច ភោជនីដ្ឋាន ផ្ទះជួល ផ្ទះសំណាក់ សណ្ឋាគារ និងស្ថានទូតជាដើម។ គេមិនដឹងច្បាស់ពីចំនួនគ្រួសារ និងប្រជាជនសរុបនៅ ក្នុងតំបន់នេះឡើយ។



តំបន់ភ្ញៀវទេសចរនៅតំបន់បឹងកក់ (រូបថតដោយ NGO Forum)

នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧ សាលាក្រុងភ្នំពេញបានប្រកាសថាខ្លួនបានព្រមជួលបឹងនេះសំរាប់រយៈពេល ៩៩ឆ្នាំ ក្នុងតំលៃ ៧៩.០០២.០០០ដុល្លា ក្នុងអត្រា ០,៦០ដុល្លា/ម$^{២}$ /ឆ្នាំ អោយទៅក្រុមហ៊ុនតូចមួយមានឈ្មោះថា Shukaku Inc សំរាប់ការអភិវឌ្ឍន៍លើផ្ទៃដីទំហំ ១៣៣ ហិកតាដោយក្នុងនោះរួមទាំងផ្ទៃបឹង ៩០ហិកតាផង។ យោងតាមកិច្ចព្រមព្រៀងជួលនេះប្រជាពលរដ្ឋប្រមាណចំនួន ៤.២៥២គ្រួសាររស់នៅក្នុងសង្កាត់ស្រះចក នៃខ័ណ្ឌដូនពេញ នឹងត្រូវរងផលប៉ះពាល់។

ក្រោយមកសាលាក្រុងភ្នំពេញបានប្រកាសថា ក្រុមហ៊ុនសំណង់ឯកជនមួយដែលមានឈ្មោះថា 7NG បានស្នើផែនការមកសាលាក្រុងភ្នំពេញដើម្បីផ្តល់ទីជំរកសំរាប់ប្រជាជនរាប់ពាន់នាក់ដែលនឹងត្រូវជម្លៀសចេញពីតំបន់បឹងកក់នៃក្រុងភ្នំពេញ[1]។ យោងតាមផែនការដែលបានស្នើឡើងនេះ គ្រួសារទាំងអស់នឹងត្រូវបានអនុញ្ញាតអោយស្នាក់នៅទីតាំងបច្ចុប្បន្ន សំរាប់រយៈពេល ០៤ឆ្នាំ ហើយត្រូវបង់ប្រាក់ចំនួន ០,៦៤ដុល្លា/ថ្ងៃ/គ្រួសារ សំរាប់ រយៈពេល ០៤ឆ្នាំ អោយទៅក្រុមហ៊ុន ទុកដូចជាប្រាក់កក់។ ក្រោយពីរយៈពេល ០៤ឆ្នាំ គ្រួសារទាំងអស់នឹងត្រូវ ផ្លាស់ទៅនៅផ្ទះថ្មី ហើយត្រូវបង់ប្រាក់ ០,៤២ដុល្លា/ថ្ងៃ/គ្រួសារ សំរាប់រយៈពេល ០៦ឆ្នាំ។ បន្ទាប់មកទើបប្រជាពលរដ្ឋទាំងនោះទទួលបានផ្ទះនេះជាកម្មសិទ្ធិ។ ដច្នេះផ្ទះថ្មីនេះមានតំលៃសរុបប្រមាណជា ១.៨៥៤ ដុល្លា គិតតាមតំលៃទីផ្សារក្នុងឆ្នាំ ២០០៧។

គេនិយាយថា ផ្ទះថ្មីនេះមានទំហំ ២០ម. x ៥ម. ប៉ុន្តែ មិនមានព័ត៌មានជាក់លាក់អំពីទីតាំងនៃដីឬផ្ទះដែលផ្តល់នេះឡើយ។ យោងតាមសំណើនេះ ផ្ទះថ្មីនេះនឹងមានផ្លូវ ភ្លើង ទឹក ប្រព័ន្ធលូ សាលារៀន មន្ទីរពេទ្យ និងវត្តអារ៉ាម។ តំណាងក្រុមហ៊ុន 7NG ម្នាក់ បាននិយាយថា នៅពេលនេះក្រុមហ៊ុនរបស់គាត់កំពុងធ្វើការជាមួយសាលាក្រុងភ្នំពេញ នៅលើគំរោងមួយដែលពាក់ព័ន្ធនឹងដីលើសពី ១.០០០ហិកតា ដែលនឹងត្រូវប្រើប្រាស់សំរាប់ផ្តល់ផ្ទះជូនប្រជាជនក្រីក្រក្នុងតំលៃសមស្រប។

## ៣. តើមានគោលបំណងអ្វីខ្លះ?

បញ្ហាជាចំបងគឺត្រូវយល់ដឹងច្បាស់អំពីគោលបំណងរបស់សាលាក្រុងភ្នំពេញជុំវិញកិច្ចព្រមព្រៀងជួល និងការអភិវឌ្ឍន៍តំបន់បឹងកក់។ ការប្រកាសព័ត៌មានស្តីពីកិច្ចព្រមព្រៀងជួលនេះមិនបានលើកឡើងពីគោលបំណងនៃការជួលឡើយ។

- តើការអភិវឌ្ឍន៍នេះមានការដោះស្រាយបញ្ហាផ្ទះសំបែងដែរឬទេ ហើយតើដោះស្រាយសំរាប់អ្នកណាខ្លះ?
- តើនេះគឺជាគំនិតផ្តួចផ្តើមមួយដើម្បីរកចំណូលសំរាប់សាលាក្រុងភ្នំពេញឬយ៉ាងណា?
- តើនេះគឺជាការខិតខំប្រឹងប្រែងដើម្បីធ្វើអោយក្រុងភ្នំពេញមានសោភ័ណភាពឬយ៉ាងណា?
- តើនេះដើម្បីធ្វើអោយប្រសើរឡើងនូវបរិស្ថានក្នុងទីក្រុងឬយ៉ាងណា?
- ឬមួយក៏មានគោលបំណងអ្វីផ្សេងពីនេះទៀត ពាក់ព័ន្ធទៅនឹងការជួលនេះ ?

គោលបំណងទាំងអស់សុទ្ធតែមានសារៈសំខាន់ ដើម្បីស្វែងយល់ពីចក្ខុវិស័យរបស់សាលាក្រុងភ្នំពេញ។ ការយល់ដឹងពីគោលបំណងទាំងនេះនឹងផ្តល់ឱកាសអោយផ្នែកផ្សេងៗ និងប្រជាពលរដ្ឋចូលរួមពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់សាលាក្រុងភ្នំពេញសំរាប់ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ។

[1] កាសែត Cambodia Daily ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៧

## ៤. ច្បាប់ភូមិបាល -ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ


ទិដ្ឋភាពបឹងកក់ (រូបថតដោយ NGO Forum)

យោងតាមមាត្រាទី១៥នៃច្បាប់ភូមិបាល ស្ទឹង ទន្លេ បឹងបួរជាដើម ត្រូវបានចាត់ទុកថាជាសម្បត្តិសាធារណៈរបស់រដ្ឋ។ មាត្រាទី១៦ និងទី១៨ នៃអនុក្រឹត្យលេខ ១២៩អនក្រ.បក. ស្តីពីវិធាននិងនីតិវិធីនៃការធ្វើចំណាត់ថ្នាក់សម្បត្តិសាធារណៈ និងអង្គភាពសាធារណៈឡើងវិញចែងថាការជួលសម្បត្តិសាធារណៈរបស់រដ្ឋត្រូវតែៈ ១/ មិនលើសពីរយៈពេល១៥ឆ្នាំ និង ២/ មិនអោយមានអន្តរាយដល់ទ្រព្យសម្បត្តិ ឬផ្លាស់ប្តូរការបំពេញមុខងាររបស់សម្បត្តិសារណៈ នោះក្នុងការផ្តល់សេវាសាធារណៈ។ ស្របតាមមាត្រាទាំងពីរនេះ បឹងកក់គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋហើយមិនអាចជួលលើសពីរយៈពេល ១៥ឆ្នាំឡើយ។ លើសពីនេះទៅទៀត យោងតាមកិច្ចព្រមព្រៀងក្រុមហ៊ុនត្រូវបានអនុញ្ញាត អោយចាក់បំពេញដីទំហំ ៨០ហិកតានៃផ្ទៃបឹង សរុប៩០ហិកតា។ នេះមានន័យថាបឹងនឹងផ្លាស់ប្តូរមុខងារទាំងស្រុង ហើយធម្មជាតិជាបឹង នឹងត្រូវប្រែក្លាយទៅជាដីស្ងួត។ ផ្អែកលើមូលដ្ឋាននេះ អ្នកច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាលកំពុងចាត់ទុកថាកិច្ចព្រមព្រៀងនេះខុសច្បាប់។

បរិមាណទឹកប្រាក់នៃការជួលនេះត្រូវបានឯកភាពពីដំបូងដោយទីស្តីការគណៈរដ្ឋមន្ត្រី។ ភាពស្របគ្នាទៅនឹងទិដ្ឋភាពច្បាប់ គឺជាដំណើរការដែលមានលក្ខណៈស្តង់ដាររបស់អាជ្ញាធរ និងអាចបញ្ជាក់បានថាទីស្តីការគណៈរដ្ឋមន្ត្រី និងសាលាក្រុងភ្នំពេញបានធ្វើដូចគ្នា។ ដូចនេះជាការគួរអោយចាប់អារម្មណ៍ចង់ដឹងខ្លាំងណាស់ពីសាលាក្រុង ភ្នំពេញថាតើច្បាប់ណាមួយដែលផ្តល់ធម្មានុរូបចំពោះកិច្ចសន្យាជួលនេះ។

## ៥. ផែនការមេរបស់សាលាក្រុងភ្នំពេញ

ផែនការមេរបស់សាលាក្រុងភ្នំពេញបានបរិយាយពីការណែនាំ ៦យ៉ាងសំរាប់ការអនុវត្តន៏។ ក្នុងចំណោមការណែនាំទាំងនោះការណែនាំមួយចែងថាៈ

*ការថែរក្សានូវអានុភាពដ៏ធំធេងៈ ការអនុម័តយកទៅតាមគល់បញ្ជីដីរបស់សាលាក្រុង ក្នុងការកំណត់ព្រំដែនអានុភាពនៃកម្មសិទ្ធិសាធារណៈ សំរាប់ជាច្រកឆ្លងកាត់នៃហេដ្ឋារចនាសម្ព័ន្ធធំៗនៃប្រព័ន្ធផ្លូវថ្នល់ ប្រឡាយ របាំងការពារខ្យល់ព្យុះ ស្ទឹង និងបរិក្ខាររចនាសម្ព័ន្ធធំៗនៃទីក្រុង (អាកាសយានដ្ឋាន កំពង់ផែ ផ្លូវដែក ទម្រង់បរិក្ខារសាធារណៈ សាកលវិទ្យាល័យ ផាក សួនឧទ្យានធំៗ តំបន់អេកូឡូស៊ី)។*

ប្រៀបធៀបការណែនាំខាងលើជាមួយផែនការប្រើប្រាស់ដីធ្លីរបស់ផែនការមេយើងអាចមើលឃើញថា ផែនការមេនេះបាននិងកំពុងការពារបឹង និងទន្លេដែលជា "របាំងខ្យល់ព្យុះ" និង "តំបន់អេកូឡូស៊ី" ដែលជាក់ស្តែងរួមមានបឹងពោងពាយ និងបឹងកក់។ ប៉ុន្តែនៅពេលនេះបឹងពោងពាយត្រូវបានចាក់ដីបំពេញអស់ទៅហើយ។ ហើយកិច្ចព្រមព្រៀងជួលតំបន់បឹងកក់នៅពេលនេះកំពុង អនុញ្ញាតអោយចាក់ដីបំពេញទំហំ ៨០ហិកតា លើផ្ទៃបឹងសរុបចំនួន ៩០ ហិកតា។ ទង្វើបែបនេះឃើញថា

មិនស្របទៅតាមផែនការមេនេះឡើយ ។ ដូច្នេះគេមិនទាន់ដឹងច្បាស់ថាតើសាលាក្រុង ភ្នំពេញកំពុងអនុវត្តទៅតាមផែនការណាមួយនោះទេ ។

រូបភាពទី ១ : ផែនទីរបស់ផែនការមេសំរាប់ការអភិវឌ្ឍន៍ក្រុងភ្នំពេញ




**តំបន់ខៀវ**
ប្រឡាយមេ
ប្រឡាយក្រោមដី
បឹង
គំរោងបន្សាបជាពល
**តំបន់បៃតង**
ឧទ្យានពណ៌បៃតង/កន្លែងកំសាន - ៤.៧០០ហិកតា
តំបន់ធម្មជាតិ - ១.៤០០ហិកតា
**ការដឹកជញ្ជូន**
បណ្តាញផ្លូវថ្នល់
ផ្លូវដែក
ស្ថានីយ៏
ផែទន្លេ
ទម្រដាក់ទំនិញ / ផែ - ៩០០ហិកតា
អាកាសយានដ្ឋាន
**តំបន់ទទួលបានការអនុគ្រោះ**
កសិកម្ម - ១០.០០០ហិកតា
ភូមិដែលមានដង់ស៊ីតេប្រជាជនទាប - ៦.០០០ហិកតា
តំបន់តាំងទីលំនៅ - ៣.៨០០ហិកតា
មជ្ឈមណ្ឌលប៉ូលពិសេសទីពីរ - ១.១០០ហិកតា
ជាយក្រុងដែលមានស្រាប់ - ៦.២០០ហិកតា
បំរុងសំរាប់បរិក្ខារសាធារណៈ - ២៣០ហិកតា
ការការពាររោងចក្របន្សាបជាតិពល - ៤៣០ហិកតា
សកម្មភាពសេដ្ឋកិច្ច - ៣.០០០ហិកតា
គំរោងសង់ទីក្រុង - ២០០០ហិកតា
តំបន់ប្រវត្តិសាស្ត្រ - ៤៧០ហិកតា

## ៦. តម្លាភាព និងបរិយាកាសប្រកួតប្រជែង និងផ្នែកឯកជន

រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយលើកទឹកចិត្តវិស័យឯកជនចំពោះការអភិវឌ្ឍន៍ ។ រីឯការអនុវត្តន៏គោលនយោបាយនេះគេអាចពិនិត្យឃើញតាមរយៈការសង្កេតនៅក្នុងវិស័យនីមួយៗរបស់សេដ្ឋកិច្ចរបស់ប្រទេស ។ ទោះជាយ៉ាងដូច្នេះក៏ដោយ ប្រទេសកម្ពុជានៅតែត្រូវការវិនិយោគឯកជនកាន់តែច្រើនថែមទៀតសំរាប់ការអភិវឌ្ឍន៍របស់ខ្លួនដូចមានចែង

នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០០៦-២០១០។ ផ្នែកដ៏សំខាន់មួយរបស់ការអភិវឌ្ឍន៍ដែលដឹកនាំដោយវិស័យឯកជនគឺដំណើរការប្រកបដោយការប្រកួតប្រជែង និងតម្លាភាព ដែលអនុញ្ញាតអោយមានវិនិយោគិនច្រើនធ្វើការប្រកួតប្រជែងដើម្បីទទួលបានកិច្ចសន្យា។ ការធ្វើទៅបានយ៉ាងដូចនេះគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពសំរាប់អោយអាជ្ញាធររាជរដ្ឋាភិបាលទទួលបានប្រសិទ្ធភាពការងារខ្ពស់និងចំណាយសមរម្យដែលបំរើដល់ផលប្រយោជន៍របស់សាលាក្រុងភ្នំពេញ។

ក្រៅពីនេះ ផ្នែកអភិបាលកិច្ចរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិចែងយ៉ាងច្បាស់ថា រាជរដ្ឋាភិបាលប្ដេជ្ញាចិត្ត "អនុវត្តតាមយ៉ាងម៉ឺងម៉ាត់នូវការដេញថ្លៃជាសាធារណៈប្រកបដោយការប្រកួតប្រជែងនិងតម្លាភាពនៅក្នុងគ្រប់កិច្ចសន្យាជួលឬការបោះបង់ចោលនូវទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់" (ចំណុច ៤.១២)។ ដូចនេះតើលក្ខណៈវិនិច្ឆ័យ និងដំណើរការបែបណាដែលត្រូវបានប្រកាន់យកក្នុងការជ្រើសរើសក្រុមហ៊ុន Shukaku សំរាប់បទប្បញ្ញត្តិនៃការជួលនេះ? ហេតុអ្វីបានជាដំណើរនេះមិនបានធ្វើជាសាធារណៈ និងមានតម្លាភាពដូចដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ?

## ៧. សេដ្ឋកិច្ចទីផ្សារសេរី និងអភិបាលកិច្ច

ផ្ទុយពីបណ្ដាប្រទេសផ្សេងទៀត ភាគច្រើននៃសហគមន៍ក្រីក្រនៅកម្ពុជាមានលក្ខណៈស្របច្បាប់បើយោងទៅតាមច្បាប់ភូមិបាលឆ្នាំ២០០១។ មានប្រភេទកម្មសិទ្ធិករ និងការជួលជាច្រើនប្រភេទនៅក្នុងតំបន់បឹងកក់ ដែលមានចាប់ពីប្រជាជនដែលរស់នៅទីនោះ រហូតដល់ប្រភេទអាជីវកម្មពាណិជ្ជកម្មដែលស្ថិតក្នុងរូបភាពកម្មសិទ្ធិ និងសិទ្ធិកាន់កាប់ជាច្រើនប្រភេទ។ នៅពេលនេះនៅមិនទាន់ច្បាស់ថាតើចំនួនប្រជាពលរដ្ឋទាំង ៤.២៥២ គ្រួសារនេះត្រូវបានគណនាយ៉ាងដូចម្ដេច ហើយតើគេធ្វើចំណាត់ថ្នាក់ប្រភេទកម្មសិទ្ធិ និងសិទ្ធិកាន់កាប់ក្នុងចំណោមគ្រួសារទាំងនេះយ៉ាងដូចម្ដេច។ ចាំបាច់ត្រូវតែបញ្ជាក់អោយបានច្បាស់ថាតើសំណងនឹងត្រូវគណនាយ៉ាងដូចម្ដេចពាក់ព័ន្ធនឹង :

១. តំលៃទីផ្សាររបស់ដីធ្លីទៅតាមទីតាំង

២. ទំហំដីដែលកាន់កាប់

៣. ប្រភេទផ្ទះ ជាដើម...

ព័ត៌មានលំអិតទាំងនេះមានសារៈសំខាន់ណាស់ដោយមានការគោរពចំពោះការការពារទ្រព្យសម្បត្តិឯកជន ដែលមានភាពចាំបាច់សំរាប់គ្រប់បរិយាកាសសុខសន្តិភាព។ ជាទូទៅគេទទួលស្គាល់ថាការរៀបចំឯកសារស្ដីពីការប្រើប្រាស់ដី និងទ្រព្យសម្បត្តិនៅមានភាពទន់ខ្សោយដែលកំពុងបង្កអោយមានបញ្ហាវិវាទដីធ្លីនៅគ្រប់ស្រទាប់សង្គម ហើយអ្នកមានទ្រព្យសម្បត្តិ និងអ្នកមាន អំណាចកំពុងរំលោភយកដីនៅគ្រប់ទីកន្លែង។ សិទ្ធិលើទ្រព្យសម្បត្តិឯកជនគឺជាកត្តាមូលដ្ឋាននៃសេដ្ឋកិច្ចទីផ្សារសេរី។ គ្រួសារទាំងអស់ខិតខំធ្វើការយ៉ាងលំបាក សន្សំលុយ ទើបអាចទទួលបានទ្រព្យសម្បត្តិខ្លះ។ ប្រសិនបើទ្រព្យសម្បត្តិទាំងនេះត្រូវបាន ដកហូតយកដោយផ្ដល់ជូននូវសំណងដែលមានតំលៃទាបដោយបង្ខិតបង្ខំ និងការដាក់សំពាធនោះ ពួកគេនឹងបាត់បង់ជំនឿ នៅលើប្រព័ន្ធគ្រប់គ្រងដែលគ្មានទស្សនៈវិស័យយូរអង្វែង និងប្រកបដោយបរិយាកាសសុខសន្តិភាព។ កំលាំង ទីផ្សារគួរតែ កំណត់តំលៃ និងការព្រមព្រៀងរវាងភាគីទាំងឡាយដែលពាក់ព័ន្ធ ក្នុងខណៈដែលតួនាទីរបស់រដ្ឋាភិបាលជាអ្នកផ្ដល់នូវ បរិយាកាសសន្តិភាព ដែលក្នុងនោះកំលាំងទីផ្សារទាំងនេះអាចដើរតួនាទីរបស់ខ្លួន ហើយអ្នកពាក់ព័ន្ធទាំងអស់អាចចរចា និងឯកភាពគ្នាដោយសន្តិវិធី។

នៅក្នុងករណីតំបន់បឹងកក់នេះ តើសាលាក្រុងភ្នំពេញអាចដើរតួនាទីជាអ្នកសម្របសម្រួលក្នុងការគ្រប់គ្រងមួយដែលក្នុងនោះទាំងក្រុមហ៊ុនឯកជន និងសហគមន៍អាចចរចាគ្នាដោយផ្ទាល់ដោយគ្មានការដាក់សំពាធ និងការបង្ខិតបង្ខំ និងយោងទៅតាមគោលការណ៍ទីផ្សារសេរីយ៉ាងដូចម្តេច?

## ៤. ការវិភាគផលប៉ះពាល់បរិស្ថាន (EIA)



សកម្មអាជីវកម្មនៅជុំវិញបឹងកក់ (រូបថតដោយ NGO Forum)

បឹង ត្រពាំង និងទន្លេ គឺជាផ្នែកមួយយ៉ាងសំខាន់សំរាប់ការបង្ហូរទឹកសំណល់ និងទប់ស្កាត់ទឹកជំនន់នៅទីក្រុងភ្នំពេញ។ លើសពីនេះទៅទៀតតំបន់លំហរនៅក្នុងតំបន់ដែលមានប្រជាជនរស់នៅច្រើនក្នុងក្រុង ដូចជាទីក្រុងភ្នំពេញនេះត្រូវបានគេ ចាត់ទុកដូចជាសួតរបស់ទីក្រុង។ នៅពេលរដូវភ្លៀងកំរិតទឹក នៅក្នុងទន្លេឡើងខ្ពស់ជាងដីនៅទីក្រុងភ្នំពេញ។ កត្តានេះធ្វើ អោយយើងមិនអាចបង្ហូរទឹកចូលទៅក្នុងទន្លេបាន។ នៅក្នុងចន្លោះពេលនេះដែលទឹកទន្លេមានកំរិតខ្ពស់ជាងប្រព័ន្ធបង្ហូរ ទឹករបស់ទីក្រុង ទឹកភ្លៀងត្រូវការទីកន្លែងសំរាប់រក្សាទុកនៅក្នុងកំឡុងពេលនេះ។ ប្រសិនបើមិនមានទីតាំងសំរាប់រក្សាទុក ទឹកភ្លៀងនេះតទៅទៀតទេនោះ (អាចជាករណីទឹកជន់លិចកើតឡើងប្រសិនបើផ្ទៃបឹង ៩០% ត្រូវបានចាក់ដីបំពេញ) ទីក្រុងភ្នំពេញនឹង រងនូវការលិចទឹកសូម្បីតែនៅពេលមានភ្លៀងតិចតួចក៏ដោយ។ មានការសំគាល់ឃើញថាមានទឹកជំនន់តាំងពីលើកដំបូងម្ល៉េះ ក្រោយពីពេលចក់ដីលុបបឹងពោងពាយ។ ក្រៅពីការបង្កាមិនអោយទីក្រុងភ្នំពេញរងនូវទឹកជំនន់ បឹងទាំងនេះផ្តល់នូវការ កែឆ្នៃបែបធម្មជាតិសំរាប់បន្សុតប្រព័ន្ធទឹកកខ្វក់របស់ទីក្រុង។ លើសពីនេះទៅទៀត ទីតាំងលំហររបស់ផ្ទៃបឹងត្រូវបានចាត់ ទុកថាជា "សួតរបស់ទីក្រុង" យ៉ាងចាំបាច់ដើម្បីលាងសំអាតខ្យល់។ ការអង្កេតឃើញចំនួនយានយន្ត ដែលចេះតែកើនឡើងនៅក្នុងទីក្រុងភ្នំពេញទាមទារអោយមានលំហរនៅក្នុងទីក្រុង។

ផែនការអភិវឌ្ឍន៍បឹងកក់នឹងមានផលប៉ះពាល់ពហុវិស័យ។ ផលប៉ះពាល់ទាំងនេះនឹងមិនមានឥទ្ធពលតែនៅក្នុងតំបន់បឹងកក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ទីក្រុងភ្នំពេញទាំងមូល។ គំរោងប្រភេទនេះទាមទារនូវ "ការវិភាគផលប៉ះពាល់បរិស្ថាន " អោយបានហ្មត់ចត់មុនធ្វើការអនុម័តគំរោង។ ដោយហេតុថាកិច្ចព្រមព្រៀងរវាងសាលាក្រុងភ្នំពេញ និងក្រុមហ៊ុន Shakuka មិនបានកំណត់អ្វីទាល់តែសោះអំពីការវិភាគផលប៉ះពាល់បរិស្ថាន និងដោយហេតុថាគ្មាន ព័ត៌មានដែលបញ្ជាក់ថាក្រុមហ៊ុន ឬអាជ្ញាធរបានធ្វើការវិភាគផលប៉ះពាល់បរិស្ថាននៅមុនកិច្ចព្រមព្រៀងនេះ វាហាក់ដូចជាស្តែងអោយឃើញថាគំរោងនេះមិនបានធ្វើការវិភាគផលប៉ះពាល់បរិស្ថានឡើយ។ ប្រសិនបើនេះគឺជាការពិតនោះ ចាំបាច់ត្រូវធ្វើការវិភាគផលប៉ះពាល់បរិស្ថាននៅក្នុងរយៈពេលខ្លីដោយភ្នាក់ងារឯករាជ្យមួយ។ ក្រោយពីបញ្ចប់ការវិភាគផលប៉ះពាល់បរិស្ថានរួចហើយលទ្ធផលទាំងអស់ត្រូវផ្សព្វផ្សាយជាសាធារណៈ អោយបានឆាប់តាមដែលអាចធ្វើទៅបាន។

## ៥. ការបន្ថែមបន្ទុកលើសលប់ មកលើហេដ្ឋារចនាសម្ព័ន្ធក្រុង

មិនមានព័ត៌មានច្រើនទេស្តីពីការអភិវឌ្ឍន៍តំបន់បឹងកក់។ ប៉ុន្តែព័ត៌មានតិចតួចបានបង្ហាញអោយឃើញពីការរៀបចំទីលំនៅសំរាប់អ្នកមាន និងអគារច្រើនជាន់។ អ្នកមានប្រើប្រាស់សេវាដូចជាអគ្គិសនី និងទឹកច្រើនជាងគ្រួសារដែលមាន

ចំណូលមធ្យម និងទាប។ លើសពីនេះទៅទៀតអគារច្រើនជាន់មានន័យថាមានប្រជាជនកាន់តែច្រើន និងមានការប្រមូលផ្តុំសកម្មភាពកាន់តែច្រើននៅក្នុងទីក្រុង។ ការអភិវឌ្ឍន៍បែបនេះនឹងនាំអោយមានបន្ទុកថែមទៀតដល់ហេដ្ឋារចនាសម្ព័ន្ធទីក្រុងដែលបានផ្ទុកហួសចំណុះទៅហើយ ដូចជាផ្លូវនៅក្នុងទីក្រុង។

ផ្លូវថ្នល់ដែលមានសព្វថ្ងៃនៅក្នុងទីប្រជុំជនក្រុងមិនមានលទ្ធភាពគ្រប់គ្រាន់នឹងសម្រួលដល់បន្ទុកចរាចរនាពេលបច្ចុប្បន្នបានឡើយ។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ទីក្រុងសព្វថ្ងៃមាន អគ្គិសនី ការផ្គត់ផ្គង់ទឹក និងការបង្ហូរទឹកជាដើមមិនមានការកែលំអអោយមានភាពប្រសើរឡើងបានឆាប់រហ័សដូចគ្នានឹងអត្រានៃការអភិវឌ្ឍន៍ទីក្រុងយ៉ាងលឿននោះបានឡើយ។ លោក អ៊ិត ប្រាង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានមានប្រសាសន៍ថា ទីក្រុង (ភ្នំពេញ) នឹងបន្តខ្វះភ្លើងចំនួន ៤០មីហ្គាវ៉ាត់ជាប្រចាំថ្ងៃរហូតដល់ពីរឆ្នាំខាងមុខទៀត[២]។ បច្ចុប្បន្ននេះ ទីក្រុងកំពុងជួបប្រទះការកកស្ទះចរាចរ ផ្តាច់ភ្លើងជាច្រើនម៉ោង លិចទឹក និងបញ្ហាផ្សេងទៀត។

សាលាក្រុងមានផែនការអភិវឌ្ឍន៍សំរាប់ទីក្រុងភ្នំពេញច្រើនថែមទៀត បន្ថែមលើគំរោងអភិវឌ្ឍន៍បឹងកក់នេះ។ ការអភិវឌ្ឍន៍ទាំងនេះមិនត្រឹមតែពាក់ព័ន្ធទៅនឹងបញ្ហាដីធ្លី និងការវិនិយោគប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់គំរោងពហុវិស័យមួយចំនួនដូចជា ហេដ្ឋរចនាសម្ព័ន្ធ ការគ្រប់គ្រងចរាចរ និងសន្តិសុខជាដើម។ ដច្នេះហើយការធ្វើសេចក្តីសំរេចមួយសមស្របស្តីពីគំរោងអភិវឌ្ឍន៍ថ្មីៗត្រូវមានការពិគ្រោះយោបល់ជាមួយស្ថាប័ននីមួយៗដែលពាក់ព័ន្ធ។ ជាការពិតសាលាក្រុងដឹងពីស្ថានភាព និងដំណើរការពិគ្រោះយោបល់ជាមួយក្រុមពាក់ព័ន្ធ។ តែអ្វីដែលប្រជាពលរដ្ឋចង់ដឹងនោះគឺថាតើមានស្ថាប័នណាខ្លះដែលសាលាក្រុងបានធ្វើការពិគ្រោះយោបល់ជាមួយនាពេលកន្លងមក? តើពួកគេយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនាពេលបច្ចុប្បន្ន? តើពួកគេយល់ឃើញយ៉ាងដូចម្តេចចំពោះការអភិវឌ្ឍន៍យ៉ាងលឿននេះ? តើស្ថាប័នទាំងនេះបានផ្តល់ជាអនុសាសន៍អ្វីខ្លះសំរាប់ការរៀបចំផែនការទៅថ្ងៃអនាគត? តើវិធានការ និងការរៀបចំហិរញ្ញវត្ថុណាខ្លះដែលតម្រូវអោយមានការកែលំអរទៅលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលមានស្រាប់ ដើម្បីដោះស្រាយការអភិវឌ្ឍន៍ទាំងនេះ? តើត្រូវរៀបចំហិរញ្ញវត្ថុចេញពីប្រភពធនធានណា និងដោយរបៀបណា?

## ១០. ការពិគ្រោះយោបល់សាធារណៈ

ដូចបានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងការពិភាក្សាខាងលើដែលថាការអភិវឌ្ឍន៍នេះមានផលប៉ះពាល់មកលើទីក្រុងទាំងមូល ហើយវាជាការត្រឹមត្រូវនិងសមហេតុផលណាស់ក្នុងការផ្តល់ព័ត៌មានពីស្ថានភាព និងច្បាស់លាស់ជូនប្រជាពលរដ្ឋអោយបានទូលំទូលាយ។ នៅក្នុងបណ្តាប្រទេសជាច្រើន ជាការប្រតិបត្តិធម្មតាក្នុងការផ្សព្វផ្សាយពតិមានដល់ប្រជាពលរដ្ឋតាមរយៈសារព័ត៌មានបោះពុម្ពជាអក្សរ និងតាមប្រព័ន្ធអេឡិកត្រូនិក ដោយអញ្ជើញប្រជាពលរដ្ឋអោយចូលរួមផ្តល់យោបល់។ ប្រជាពលរដ្ឋមានឱកាសសំដែងនូវមតិយោបល់របស់ពួកគេតាមវិធីជាច្រើន។ ការជួបជុំជាសាធារណៈបន្តបន្ទាប់គ្នាអាចជួយយ៉ាងច្រើនក្នុងការប្រមូលព័ត៌មាន និងធ្វើវិភាគផែនការ។ ធ្វើយ៉ាងដូចនេះនឹងជួយត្រួសត្រាយផ្លូវអោយមានការពិភាក្សា និង ការប្រាស្រ័យទាក់ទងគ្នាប្រកបដោយន័យស្ថាបនារវាងអាជ្ញាធរ និងប្រជាពលរដ្ឋ និងរវាងប្រជាពលរដ្ឋខ្លួនឯង។

មានកង្វល់ និងពាក្យចចាមអារ៉ាមមួយចំនួនពាក់ព័ន្ធនឹងផែនការអភិវឌ្ឍន៍បឹងកក់។ ភាគច្រើនគឺបណ្តាលមកពីព័ត៌មានតិចតួចស្តីពីផែនការ និងខ្វះការពិគ្រោះយោបល់។ ទីក្រុងនេះជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់គ្នា ហើយ

---

[2] កាសែត Cambodia Daily ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៧

ប្រជាពលរដ្ឋម្នាក់ៗត្រូវពេញចិត្តនឹងការអភិវឌ្ឍន៍នេះ ប៉ុន្តែទាមទារអោយមានកិច្ចខិតខំប្រឹងប្រែងដើម្បី ពង្រឹងបរិយាកាសពិភាក្សា និងការប្រាស្រ័យទាក់ទងប្រកបដោយការស្ថាបនា។ តើគេមិនអាចនឹងអញ្ជើញ សាលាក្រុង និងក្រុមហ៊ុនឯកជន Shakaku Inc អោយបង្ហាញផែនការរបស់គេនៅក្នុងវេទិកាមួយក្នុងទីក្រុងដែល មានអ្នកចូលរួមមកពីគ្រប់មជ្ឈដ្ឋានបានទេឬ? តើសារព័ត៌មានបោះពុម្ព និងអេឡិកត្រូនិក មិនអាចជួយសាលាក្រុងអោយផ្សព្វផ្សាយផែនការទៅដល់ប្រជាជនកាន់តែច្រើននៅក្នុងទីក្រុងភ្នំពេញ និងប្រមូលយោបល់របស់ពួក គេបានទេឬ? តើសាលាក្រុងមិនអាចជំរុញអោយ "សង្គមស៊ីវិល" ផ្សព្វផ្សាយ និងពិភាក្សា អំពីផែនការនេះនៅក្នុង មជ្ឈដ្ឋានផ្សេងៗនៅក្នុងទីក្រុងបានទេឬ? តើសាលាក្រុងដោយមានជំនួយពីសង្គមស៊ីវិល មិនអាចរៀបចំដំណើរការ ពិគ្រោះយោបល់ និងការកាត់សេចក្តីជាសាធារណៈបានទេឬ?

## ១១. គោលនយោបាយសំរាប់ការតាំងទីលំនៅថ្មី


កងកំលាំងពង្រាយសំរាប់បណ្តេញប្រជាជនចេញ និងការពារមិនអោយប្រជាជនជួបជុំគ្នា។ (រូបថតដោយ NGO Forum )

ទិដ្ឋភាពសំខាន់មួយទៀតនៃការអភិវឌ្ឍន៍ ដូចជាផែនការអភិវឌ្ឍន៍បឹងកក់នេះ ដែលនឹងប៉ះពាល់ដល់ប្រជាពលរដ្ឋរាប់ពាន់គ្រួសារ គឺគោលនយោបាយសំរាប់ការតាំងទីលំនៅថ្មីដែលកំណត់ច្បាស់លាស់នូវលក្ខណៈវិនិច្ឆ័យនិងដំណើរការសំរាប់ការតាំងទីលំនៅថ្មីដែលនឹងត្រូវធ្វើឡើងផ្តល់ព័ត៌មានពីស្ថានិងដំណើរការនៃការផ្តល់សំណង ការរៀបចំ ហិរញ្ញវត្ថុ និងការពិគ្រោះយោបល់ជាមួយគ្រួសារ និងអាជីវកម្មដែលរងផលប៉ះពាល់។ នៅពេលនេះគ្មានគោលនយោបាយជាតិសំរាប់ការតាំងទីលំនៅថ្មីឡើយ។ ប៉ុន្តែសាលាក្រុងភ្នំពេញធ្លាប់បានធ្វើគំរូល្អៗបំផុតនៃ ការតាំងទីលំនៅថ្មីដូចជានៅតំបន់អភិវឌ្ឍន៍មានជ័យ គោកឃ្លេង ១ និង គោកឃ្លេង ២ ដែលបានគាំទ្រដោយម្ចាស់ជំនួយ និងNGOs។ ក្រោយមកគោលការណ៍សំរាប់ការតាំងទីលំនៅថ្មីនៅក្នុងតំបន់ទាំងបីនេះ មិនត្រូវបានអនុវត្តទៀតឡើយដោយសារហេតុផលពីរសំខាន់ រឺ ទីមួយ ការអនុវត្តន៍ទាំងនេះមិនដែលប្រែក្លាយអោយទៅជាគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ការរៀបចំស្ថាប័ន ការកសាងសមត្ថភាព និងការរៀបចំផ្តល់ជូនឡើយ និងទីពីរ គំរូនៃការផ្លាស់ប្តូរទីលំនៅទាំងនេះ មិនបានផ្តល់នូវជំរើស នៃការរៀបចំហិរញ្ញវត្ថុប្រកប ដោយនិរន្តរភាពដែលអាចជំនួសការគាំទ្រហិរញ្ញវត្ថុ ដែលផ្តល់ដោយ NGOs និងម្ចាស់ជំនួយឡើយ។ ក្រោយមកនៅពេល ដែលម្ចាស់ជំនួយ និងNGOs មានភាពស្ទាក់ស្ទើរក្នុងការផ្តល់ការគាំទ្រហិរញ្ញវត្ថុ ចំពោះការផ្លាស់ប្តូរទីលំនៅបន្ថែម ទៀតនោះគ្មាន ការរៀបចំហិរញ្ញវត្ថុជំនួសផ្សេងទៀតសំរាប់ការផ្លាស់ប្តូរទីលំនៅថ្មីៗទាំងនេះ ហើយសហគមន៍ទាំងឡាយត្រូវ បានបង្ខំអោយរស់នៅលើទីតាំងដែលគ្មាន ឬមានបរិក្ខារមិនសមរម្យ។

បទពិសោធន៏ក្នុងពេលកន្លងមកមានសារៈសំខាន់យ៉ាងខ្លាំងសំរាប់អានសិក្សា ប្រសិនបើយើងបានត្រៀមខ្លួនដើម្បីវាយតំលៃលើ ការខិតខំប្រឹងប្រែងរបស់យើងដោយបើកចំហរ។ ការពិនិត្យមើលទៅលើគំរូជោគជ័យនៃការផ្លាស់ប្តូរទីលំនៅកាលពីពេល កន្លងមក តើយើងត្រូវធ្វើអ្វីខ្លះដើម្បីកសាងគោលនយោបាយរុះរើតាំងទីលំនៅថ្មី? តើមានលក្ខខណ្ឌអ្វីខ្លះសំរាប់ការបណ្តេញចេញ/ការផ្លាស់ប្តូរទីលំនៅដែលជាជំរើសចុងក្រោយសំរាប់ការអភិវឌ្ឍន៍ណាមួយ? តើចំណាយក្នុងការផ្តល់សំណង/ការផ្លាស់ប្តូរទីលំនៅអាចបញ្ចូលជាផ្នែកមួយសំខាន់នៃគំរោងអភិវឌ្ឍន៍ជាផែនការអភិវឌ្ឍន៍បឹងកក់បានដែរឬទេ? តើគួរមាន

ក្របខ័ណ្ឌច្បាប់ និងការរៀបចំស្ថាប័នដូចម្ដេចខ្លះ? តើគួរមានដំណើរការ បែបណាដែលផ្ដោតលើការចូលរួមរបស់សហគមន៍ ថាជាធាតុមួយសំខាន់ ?

## ១២. សន្តិសុខកម្មសិទ្ធិដីធ្លីសំរាប់សហគមន៍

កាលពីខែឧសភា ឆ្នាំ២០០៣ ការប្រកាសថានឹងលើកកំពស់ការរស់នៅរបស់សហគមន៍ចំនួន ១០០គ្រួសារ ក្នុងមួយឆ្នាំ និងធ្វើឱ្យមានសន្តិសុខ និងសុវត្ថិភាពលើកម្មសិទ្ធិសំរាប់ការផ្លាស់ប្តូរទីលំនៅសំរាប់អ្នកក្រ ថ្លែងដោយសម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។ សារនេះត្រូវបានកោតសរសើរ ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ ដោយម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ។ ម្ចាស់ជំនួយ អង្គការមិនមែន រដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាច្រើនបានចំណាយទឹកប្រាក់រាប់លានដុល្លា ក្នុងការលើកកំពស់ ការតាំងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋរាប់រយគ្រួសារ ដើម្បីគាំទ្រដល់ការប្តេជ្ញាចិត្តនេះ។ កាលពីខែមីនា ឆ្នាំ២០០៧ ថ្មីៗនេះម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដដែល មានការភ្ញាក់ផ្អើលនឹងទិដ្ឋភាពនៃការបណ្ដេញប្រជាពលរដ្ឋ ចេញពីលំនៅដ្ឋានជាបន្តបន្ទាប់ ហើយបានចោទសួរអំពីការវិនិយោគដែលពួកគេបានធ្វើឡើងក្នុងក្ដីសង្ឃឹមថានឹងមាន សន្តិសុខកម្មសិទ្ធិសំរាប់ សហគមន៍ក្រីក្រ ។


សំណង់អគារជុំវិញតំបន់បឹងកក់
(រូបថតដោយ NGO Forum)

គួរកត់សំគាល់ថា សហគមន៍ក្រីក្រនៅជុំវិញបឹងកក់ក៏ទទួលបានផលប្រយោជន៍ពីការលើកកំពស់ការរស់នៅនេះដែរ។ បើទោះបីជាគំរោងសាកល្បងដែលបានក្លាយជាមូលដ្ឋានសំរាប់គំនិតផ្តួចផ្តើមដើម្បីលើកកំពស់ការរស់នៅនេះ បានអនុវត្តចំពោះករណីការតាំងទីលំនៅនៅតំបន់រស់រាយ នៅក្នុងសង្កាត់ស្រះចកដូចគ្នានេះ ហើយដែលបច្ចុប្បន្ននេះត្រូវបានជួលអោយទៅក្រុមហ៊ុនឯកជន។ សហគមន៍ទាំងនេះមានអារម្មណ៍សុវត្ថិភាពដោយសារហេតុផលពីរគឺ: ទីមួយ ពួកគេគិតថាការលើកកំពស់ការរស់នៅមានន័យថាគេទទួលស្គាល់សិទ្ធិរបស់ពួកគេក្នុងការរស់នៅលើទីតាំងនេះ ។ ទីពីរ បឹងកក់គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ហើយមិនអាចជួលអោយវិស័យផ្នែកឯកជនបានឡើយ ។ ឥឡូវនេះពួកគេចោទសួរថាតើមានច្បាប់ណាមួយដែលអនុញ្ញាតអោយមានការជួលបឹងកក់ក្នុងរយៈពេល៩៩ឆ្នាំ ទៅអោយផ្នែកឯកជន? បន្ទាប់មកសួរទៀតថាហេតុអ្វីបានជាអាជ្ញាធរមិនពិចារណាផ្តល់ការជួលនេះអោយទៅ ប្រជាជននៅមូលដ្ឋាននៅមុនពេល ធ្វើកិច្ចព្រមព្រៀងជាមួយផ្នែកឯកជន ?

## ១៣. បរិមាណទឹកប្រាក់សំណង

ប្រសិនបើយើងគិតថាបរិមាណប្រាក់ទាំងអស់ចំនួន ៧៩.០០២.០០០ (ចិតសិបប្រាំបួនលានពីរពាន់)ដុល្លា នឹងត្រូវបានប្រើប្រាស់សំរាប់ ការផ្តល់សំណងសំរាប់ប្រជាពលរដ្ឋ ៤.២៥២ (មួយពាន់ពីររយ)គ្រួសារ ដែលគ្រួសារនីមួយៗនឹងទទួលបានជាមធ្យមចំនួន ១៨.៥៨៨ (មួយម៉ឺនប្រាំបីពាន់ប្រាំរយបែតសិបប្រាំបី)ដុល្លា។ ប្រសិនបើយើងពិចារណាលើតំលៃ ៤០០ (បួនរយ)ដុល្លា/ម$^{២}$ (ទាបជាងតំលៃទីផ្សារ) ជាសំណងសំរាប់តែដី នោះទឹក ប្រាក់ ១៨.៥៨៨ដុល្លាអាចគ្រប់គ្រាន់សំរាប់តែ ៤៦,៤៧ម$^{២}$ ប៉ុណ្ណោះ។ ប្រសិនបើយើងបន្ថែមតំលៃនៃ រចនាសម្ព័ន្ធ ដែលមាននៅលើដី ពេលនោះយើងនឹងឃើញថាទឹកប្រាក់នេះហាក់ដូចជាមិនគ្រប់គ្រាន់សំរាប់សំណងដែលប្រសើរនោះទេ។

កិច្ចព្រមព្រៀងមិនបញ្ជាក់ពីទឹកប្រាក់សរុប ដែលបែងចែកសំរាប់សំណងឡើយ។ ប៉ុន្តែកិច្ចព្រមព្រៀងបានលើកឡើងថាទឹកប្រាក់សំណងនឹងត្រូវផ្តល់ជូនពីទឹកប្រាក់នៃកិច្ចព្រមព្រៀងចំនួន ៧៩.០០២.០០០ដុល្លា ដែលមាន ន័យថាត្រឹមតែផ្នែក

មួយប៉ុណ្ណោះនៃទឹកប្រាក់កិច្ចព្រមព្រៀង នឹងត្រូវរំលែកសំរាប់ការផ្តល់សំណង។ ហេតុនេះតើមានលក្ខណៈវិនិច្ឆ័យ និងដំណើរការដូចម្តេចសំរាប់ការផ្តល់សំណង? តើសមរម្យទេក្នុងការផ្តល់សំណងនូវទឹកប្រាក់តិចតួចនេះដល់គ្រួសារដែលរងផលប៉ះពាល់?

**១៩. ដោយអនុវត្ត “យុទ្ធសាស្ត្រអភិវឌ្ឍន៍គាំទ្រដល់អ្នកក្រ” សាលាក្រុងភ្នំពេញមានចំណូលកាន់តែប្រសើរ**

យោងតាមកិច្ចព្រមព្រៀង ថ្លៃជួលសរុបចំនួន ៧៩.00២.000ដុល្លា នឹងត្រូវបង់ទៅអោយសាលាក្រុងភ្នំពេញក្នុងរយៈពេល ១0ឆ្នាំ ។ បើបែងចែកទឹកប្រាក់ដដែលនេះជាមួយនឹង ៤.២៥២ គ្រួសារ នោះប្រជាពលរដ្ឋ ទទួលបានទឹកប្រាក់ ១៨.៥៧៦,៩៦ដុល្លា/គ្រួសារ ។ គិតរយៈពេល ១0ឆ្នាំខាងមុខនេះ ចំនួននេះ ត្រូវជា ១.៨៥៨ ដុល្លា/គ្រួសារ/ឆ្នាំ គិតតាមតំលៃទីផ្សារបច្ចុប្បន្ន ។ លទ្ធភាពជំរើសមួយគឺផ្តល់ការជួលដូចគ្នានេះ ទៅអ្នកកាន់កាប់សព្វថ្ងៃ ដែលទំនងជាមានចំណាប់អារម្មណ៏ខ្លាំងក្នុងការបង់ប្រាក់នេះ។ សេណារីយ៉ូជំនួសនេះអាចល្អ សំរាប់មុខមាត់ក្នុងស្រុក និងអន្តរជាតិ របស់សាលាក្រុងភ្នំពេញ ដោយហេតុថាខ្លួនចៀសវាងបាននូវការបណ្តេញចេញប្រជាពលរដ្ឋរាប់ពាន់គ្រួសារ ។ តាមរយៈការផ្តល់កិច្ចសន្យាជួលនេះទៅអោយប្រជាពលរដ្ឋគេនឹងទទួលបាននូវ ស្ថានភាពឈ្នះ-ឈ្នះសំរាប់ទាំងសាលាក្រុងភ្នំពេញ និងប្រជាពលរដ្ឋដែលរស់នៅទីនោះសព្វថ្ងៃព្រោះថាសាលាក្រុង ភ្នំពេញទទួលបានចំនួនទឹកប្រាក់ដូចគ្នាហើយបាន ផ្តល់សន្តិសុខកម្មសិទ្ធិចំពោះអ្នកកាន់កាប់នៅមូលដ្ឋាន និងទទួលបានមុខមាត់ ” ជួយដល់អ្នកក្រ ” ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។

លើសពីនេះទៅទៀត ម្ចាស់ជំនួយជាច្រើននឹងចេញមកជួយផែនការសាលាក្រុងភ្នំពេញ ដើម្បីប្រែក្លាយបឹងកក់ទៅជានិមិត្តរូបនៃ ”ការអភិវឌ្ឍន៏ និងការធ្វើអោយមានសោភ័ណភាព ” ទីក្រុងដែលមាន ”យុទ្ធសាស្ត្រអភិវឌ្ឍន៏ជួយដល់អ្នកក្រ” ។ មានបច្ចេកទេសទាប និងជំរើសក្នុងការចំណាយតិចជាច្រើនសំរាប់ករណីនេះ។ នៅប្រទេសថៃមានឧទាហរណ៏មួយចំនួនដែលក្នុងនោះសហគមន៏បានទទួលខុសត្រូវក្នុងការសំអាតប្រឡាយ និងផ្លាស់ប្តូរប្រឡាយពីទឹកពណ៌ខ្មៅអោយទៅជាពណ៌ខៀវ។ សហគមន៏អាចធ្វើរឿងអស្ចារ្យ ប៉ុន្តែបញ្ហាចោទសំខាន់គឺថាតើ យើងប្តេជ្ញាចិត្តបានក៏រិតណាចំពោះ ”យុទ្ធសាស្ត្រអភិវឌ្ឍន៏ជួយដល់អ្នកក្រ” សំរាប់ ”ការកាត់បន្ថយភាព ក្រីក្រ” ។

## សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនង:


ក្រុមការងារសិទ្ធិលំនៅដ្ឋាន

លោក Rashid Kharti

ទូរស័ព្ទលេខ : 0១២ ៤៧២ ៩0៩

អ៊ីម៉ែល : khatriab@yahoo.com

លោក ផាន់ ស៊ីថន

លេខាធិការដ្ឋានក្រុមការងារសិទ្ធិលំនៅដ្ឋាន

ការិយាល័យ : ផ្ទះលេខ ៥៤ ផ្លូវ ៣0៦

ប្រអប់សំបុត្រ : ១១២0 ភ្នំពេញ កម្ពុជា

ទូរស័ព្ទ/ទូសារៈ (៨៥៥) ២៣ ២១១ ៧២៣

ការិយាល័យ : (៨៥៥) ២៣ ២១៥ ៥៩0

ទូរស័ព្ទដៃ : (៨៥៥) ១២ ៧0៧ ៩៦0

អ៊ីម៉ែល : cam.hrtf@gmail.com

# ថវិកាជាតិកម្ពុជា[៣] និងការអភិវឌ្ឍន៍:

## ការប្រែក្លាយគោលនយោបាយឱ្យទៅជាសកម្មភាពជាក់ស្តែង - ជ្រើសរើសអាទិភាពក្នុងចំណោមអាទិភាព!!

### *សង្ខេបរបាយការណ៍*

*គំរោងតាមដានថវិការបស់វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានធ្វើការវិភាគលើការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះគោលនយោបាយគាំទ្រជនក្រីក្ររបស់ខ្លួនតាមរយៈការវិភាជន៍ និងការចំណាយថវិកាជាតិក្នុងកំឡុងឆ្នាំ ២០០៦ និងការវិភាជន៍របស់ខ្លួនសំរាប់ឆ្នាំ២០០៧ ។ ការវិភាគនេះបានរកឃើញលទ្ធផលដូចតទៅ :*

1. *ការវិភាជន៍នៅក្នុងច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ គឺជាការរីកចំរើនមួយបើប្រៀបធៀបជាមួយឆ្នាំ២០០៦ ដោយការវិភាជន៍មានចំនួនកើនឡើងសំរាប់ការចំណាយ (ចរន្ត និងមូលធន) នៅក្នុងវិស័យអាទិភាព មួយចំនួន ។*
2. *ទោះជាយ៉ាងណាក៏ដោយ ការវិភាជន៍ដែលត្រូវបានបង្កើនទាំងនេះមិនបានប្រែក្លាយទៅជាចំណាយជាក់ស្តែងដូចដែលបានសន្និដ្ឋានពីទិន្នន័យចំណាយឆ្នាំ២០០៦ ឡើយ ។*
3. *ខណៈដែលចំណាយលើបៀវត្ស និងចំណាយចរន្តផ្សេងទៀតនៅក្នុងវិស័យអាទិភាពទាំងប្រាំពីរ ត្រូវបានធ្វើចំគោលដៅបន្តិចម្តងៗក្នុងកំឡុងឆ្នាំ២០០៦ ការបើកចំណាយសំរាប់ចំណាយចរន្តនៅក្នុងវិស័យទាំងនេះនៅមានភាពយឺតយ៉ាវនៅឡើយ ។*
4. *ការវិភាគលើការចំណាយរបស់រដ្ឋាភិបាលបង្ហាញឱ្យដឹងថាក្រសួង/ស្ថាប័ន "ដែលមិនមែនជាអាទិភាព" បានចំណាយលើសពីការគ្រោងទុកអស់ជាង៩០ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៦ ។*

*អត្ថបទនេះ ធ្វើការសន្និដ្ឋានជាមួយនឹងការសង្កេតថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់ព័ត៌មានតិចតួចបំផុតអំពីការវិភាជន៍ និងការចំណាយថវិកា ។ ការពិពណ៌នាដែលពន្យល់អំពីជំរើសរបស់រាជរដ្ឋាភិបាលលើថវិកាក៏មិនមានដែរ ។ ជាមួយនឹងព័ត៌មានដ៏តិចតួចនេះ វាជាការពិបាកក្នុងការវាយតម្លៃ (evaluate) លើ "ភាពគាំទ្រជនក្រីក្រ" របស់ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ហើយអង្គការមិនមែនរដ្ឋាភិបាលសូមស្នើឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់ទិន្នន័យថែមទៀតអំពីការវិភាជន៍ និងការអនុវត្តន៍ថវិកា ។ ជាមួយនេះដែរសូមផ្តល់យោបល់ថាច្បាប់សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ២០០៨ គួរភ្ជាប់មកជាមួយនូវការ ពិពណ៌នាលំអិតដែលពន្យល់អំពីជំរើស និងអាទិភាពរបស់រដ្ឋាភិបាល ។ ពាក់ព័ន្ធនឹងច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៨ អង្គការមិនមែនរដ្ឋាភិបាល សូមស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជាអនុវត្តថវិកាស្របតាមច្បាប់នេះ និងជ្រើសរើសអាទិភាពលើអាទិភាពរបស់ខ្លួន ។*

---

[៣] *ថវិកាជាតិ* គឺជាសេចក្តីថ្លែងអំពីបរិមាណនៃចំណូល និងចំណាយដែលបានគ្រោងទុករបស់រដ្ឋាភិបាលសំរាប់រយៈពេលមួយឆ្នាំ ។ ទោះជាយ៉ាងណាក្តីនៅក្នុងដំណាក់កាលនេះទំហំនៃគំរោងតាមដានថវិការបស់វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាមានព្រំដែនទៅលើតែផ្នែកចំណាយនៃថវិកាប៉ុណ្ណោះ ។ ដូច្នេះអត្ថបទនេះដែលជាផ្នែកមួយនៃសកម្មភាពរបស់គំរោងនិយាយជាក់លាក់អំពីការចំណាយតែម្យ៉ាងប៉ុណ្ណោះ ដោយទុកចំណូលសំរាប់សកម្មភាពបន្ថែមទៀត ។

## សេចក្តីផ្តើម

និយមន័យពិតប្រាកដថា តើអ្វីជាការចំណាយ[៤] នៅក្នុងថវិកា "ដែលគាំទ្រជនក្រីក្រ" នោះមិនមានឡើយ ។ ក៏ប៉ុន្តែមានការយល់ព្រមជាទូទៅថា ការចំណាយដែលមានបំណងលើកទឹកចិត្តដល់កសិកម្មខ្នាតតូច លើកកំពស់ការថែទាំសុខភាពជាមូលដ្ឋានគាំទ្រចំពោះការអប់រំបឋម និងមធ្យមសិក្សា កែលំអលទ្ធភាពប្រើប្រាស់ទឹកស្អាត និងអនាម័យចាត់ចូលក្នុងនិយមន័យប្រភេទនេះ ។ ដោយព្យាយាមតំរង់គោលនយោបាយរបស់រដ្ឋាភិបាលទៅនឹងទស្សនៈនៃភាពគាំទ្រជនក្រីក្រខាងលើអត្ថបទនេះពិនិត្យលើចំណាយនៃថវិកាឆ្នាំ២០០៧នៅក្នុងវិស័យអាទិភាពទាំងប្រាំពីរដែលកំណត់ដោយរដ្ឋាភិបាលដែលមានដូចជា វិស័យសុខាភិបាល វិស័យអប់រំ កិច្ចការនារី កសិកម្ម អភិវឌ្ឍន៍ជនបទ សាធារណៈការ និងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ លើសពីនេះទៀត អត្ថបទនេះវាយតម្លៃលើភាពជឿទុកចិត្តបាននៃថវិកានៅក្នុងវិស័យអាទិភាពទាំងនេះ និងប្រៀបធៀបភាពជឿទុកចិត្តនេះជាមួយការអនុវត្តន៍ថវិកានៅក្នុងក្រសួង/ស្ថាប័ន "ដែលមិនមែនជាអាទិភាព" ។

## ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧

### ថវិកាចំណាយមូលធនសំរាប់ឆ្នាំ២០០៧




រូបភាពទី១: ការវិភាជន៍សំរាប់ការវិនិយោគមូលធនលើវិស័យអាទិភាព '០៦ និង០៧' ក្នុងតំលៃឆ្នាំ ២០០៧ (គិតជាលានរៀល)

*(ប្រភព : ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ និង២០០៧)*

ប្រៀបធៀបជាមួយច្បាប់ថវិកាឆ្នាំ២០០៦ ចំណាយមូលធនពិតនៅក្នុងច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ បានកើនឡើង២៥% ដែលមានន័យថាជាទូទៅមានលុយច្រើនសំរាប់បញ្ហាទាំងឡាយដូចជាការសាងសង់ ការជួសជុលកែលំអ ការជួសជុលធំដុំលើអគារ និងការទិញឧបករណ៍បរិក្ខារ ។ ជារួមចំណុចនេះត្រូវបានមើលឃើញថាជាសញ្ញាវិជ្ជមានមួយ ពីព្រោះចំណាយមូលធនត្រូវបានចាត់ទុកថាជាកត្តាជំរុញមួយនៃការអភិវឌ្ឍន៍ពិតប្រាកដ ។

ទោះបីជាយ៉ាងណាក៏ដោយ ដូចបានបង្ហាញនៅក្នុងរូបភាពទី១ រូបភាពសំរាប់វិស័យអាទិភាពនៅក្នុងច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧មានភាពចំរុះ ។ ក្នុងចំណោមក្រសួងអាទិភាពទាំងប្រាំពីរមានក្រសួងតែបីប៉ុណ្ណោះទទួលបាននូវការកើនឡើងលើសពីមធ្យមក្រសួងមួយទទួលតិចជាងកំណើនមធ្យម ចំណែកក្រសួងបីទៀតមានការថយ ចុះនូវថវិកាមូលធន

---

៤ នៅក្នុងការចំណាយ ពាក្យគន្លឹះពីរត្រូវការឱ្យមានការពន្យល់ច្បាស់លាស់ - ចំណាយចរន្ត និងចំណាយមូលធន ។ *ចំណាយចរន្ត* ទាក់ទង ទៅនឹងការចំណាយលើទំនិញ និងសេវាដែលត្រូវបានប្រើប្រាស់នៅក្នុងឆ្នាំបច្ចុប្បន្ន ដូចជាប្រាក់ឈ្នួល ប្រាក់បៀវត្ស ប្រាក់សោធន ។ *ចំណាយ មូលធន* ទាក់ទងទៅនឹងការចំណាយជាទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ម្តងហើយម្តងទៀតនៅក្នុងដំណើរការផលិត ក្នុងកំឡុងពេលលើសពីមួយឆ្នាំ ។ វាបញ្ចូលការចំណាយផ្សេងៗដូចជាការសាងសង់ ការជួសជុលកែលំអ និងការ ជួសជុលធំដុំលើអាគារ និងការទិញឧបករណ៍-បរិក្ខារថ្មីជំនួសឧបករណ៍-បរិក្ខារចាស់ៗ ជាដើម ។

របស់ខ្លួនសំរាប់ឆ្នាំ២០០៧ បើប្រៀបធៀបជាមួយឆ្នាំ២០០៦។ តាមការកំណត់មានតែនាម[៥] ច្បាប់ថវិកាឆ្នាំ២០០៧ បង្ហាញពីការកើនឡើងលើចំណាយមូលធនសំរាប់ក្រសួងសុខាភិបាល (+១៦%) អប់រំ យុវជន និងកីឡា (+៩៤%) កសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ (+៣៤%) និង អភិវឌ្ឍន៍ជនបទ (+៣១%) ចំណែកការវិភាជន៍ដែលត្រូវបានកាត់បន្ថយគឺសំរាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (-៩៥%) សាធា-រណៈការ និងដឹកជញ្ជូន (-២២%) និងក្រសួងកិច្ចការនារី (-៣%)។

ទោះជាមិនទាន់មានការ វិភាគលំអិតអំពីភាពគាំទ្រជនក្រីក្រពិតប្រាកដនៃចំណាយតាមផែនការ នៅក្នុងវិស័យសុខា-ភិបាល អប់រំ កសិកម្ម និងអភិវឌ្ឍន៍ជនបទបានក៏ដោយ ការវិភាជន៍ដែលត្រូវបានបង្កើនហាក់ដូចជាជំហានមួយចំទិសដៅ។ ប៉ុន្តែចេតនារបស់រដ្ឋាភិបាលចំពោះការវិភាជន៍ថវិកាដែលកើនឡើងទាំងនេះគួរតែត្រូវបានផ្សព្វ ផ្សាយជាសាធារណៈនៅក្នុងការពិពណ៌នាមួយដែលភ្ជាប់ជាមួយច្បាប់ថវិកាដែលក្នុងនោះការកាត់បន្ថយលើថវិកាមូលធនសំរាប់ក្រសួងអាទិភាពបីទៀតដែលបានពោលខាងលើត្រូវបានបំភ្លឺផងដែរ។

## ខ្ទង់ថវិកាចំណាយចរន្តសំរាប់២០០៧

ទោះបីជាវាជាការសមហេតុផលក្នុងការរំពឹងថាការបង្កើនថវិកាប្រចាំឆ្នាំនៅក្នុងក្រសួងអាទិភាពទាំងប្រាំពីរនឹងលើសពីកំរិតមធ្យមក៏ដោយវាមិនអាចទៅរួចទេសំរាប់ចំណាយចរន្តនៅក្នុងច្បាប់ថវិកាឆ្នាំ២០០៧។ បើប្រៀបធៀបជាមួយការកើនឡើងនៃចំណាយចរន្តជាមធ្យមពិតប្រាកដចំនួន១៤ភាគរយនោះមានក្រសួងអាទិភាពតែបួនប៉ុណ្ណោះបានទទួលនូវការកើនឡើងលើមធ្យមនៃចំណាយចរន្តដែលរួមមានក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (+៣៥ភាគរយ) ក្រសួងសុខាភិបាល (+២៥ភាគរយ) ក្រសួងអប់រំ យុវជន និងកីឡា (+២០ភាគរយ) និងក្រសួងកិច្ចការនារី (+១៨ភាគរយ។ ក្រសួងដែលទទួលបានការកើន ឡើងក្រោមមធ្យមរួមមានក្រសួងសាធារណៈការនិងដឹកជញ្ជូន (+១១ភាគរយ) ក្រសួងអភិវឌ្ឍន៍ជនបទ (+៩ភាគរយ) និងក្រសួងកសិកម្ម (+២ភាគរយ)។

**រូបភាពទី២:** ការវិភាជន៍សំរាប់ការចំណាយចរន្តលើវិស័យអាទិភាព '០៦ និង០៧'
ក្នុងតំលៃឆ្នាំ ២០០៧ (គិតជាលានរៀល)




*(ប្រភព : ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ និង២០០៧)*

ទោះបីជាមានតែ១ភាគ៣នៃចំណាយចរន្តដោះស្រាយបញ្ហាប្រាក់ឈ្នួលក៏ដោយ ការវិភាជន៍ដែលកើនឡើងសំរាប់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល និងក្រសួងអប់រំ ត្រូវបានមើលឃើញថាជាការអភិវឌ្ឍន៍ជាវិជ្ជមានមួយពីព្រោះវាបង្ហាញនូវការកើនឡើងនៃចំនួនអ្នកផ្តល់សេវានៅក្នុងវិស័យទាំងនេះ និង/ឬ ល័ក្ខខ័ណ្ឌការងារល្អប្រសើរសំរាប់អ្នកផ្តល់សេវា។

---

៥ ពេលដែលចំនួនមួយ ត្រូវបានដកស្រង់ "មានតែនាម" គេមិនទាន់បានតំរូវចំនួននោះដោយគិតពីអតិផរណានៅឡើយទេ ។ នៅពេលដែលចំនួនមួយត្រូវបានដកស្រង់ជា "ពិត" អតិផរណា ត្រូវបានគិតហើយ ហើយតំលៃត្រូវបានកែតំរូវស្របតាមនោះ។

កង្វល់ដែលអាចមាន គឺការបង្កើនចំណាយដ៏តិចតួចសំរាប់ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរតែពន្យល់ឱ្យបានច្បាស់ ។

## ភាពជឿទុកចិត្តបាននៃការវិភាជន៍ឆ្នាំ២០០៧

ទោះបីជាការវិភាជន៍ឆ្នាំ២០០៧ ជារួមត្រូវបានមើលឃើញថាជាជំហានជាវិជ្ជមានមួយឈានទៅរកថវិកាមួយដែលល្អប្រសើរសំរាប់ជនក្រីក្រក៏ដោយ ក៏បទពិសោធន៍ប្រាប់យើងថាការវិភាជន៍នៅក្នុងច្បាប់ថវិកាសំរាប់ការគ្រប់គ្រង ឆ្នាំ២០០៧ អាចខុសគ្នាដ៏គួរឱ្យកត់សំគាល់ពីការចំណាយជាក់ស្តែង ជាពិសេសសំរាប់ចំណាយមូលធន ។ ដើម្បីបំភ្លឺលើចំណុចនេះ រូបភាពទី៣ខាងក្រោម បង្ហាញអំពីចំណែកនៃចំណាយជាក់ស្តែងសំរាប់ក្រសួងអាទិភាពសំរាប់ទាំងចំណាយមូលធន និងចំណាយចរន្ត ក្នុងឆ្នាំ២០០៦ ។

រូបភាពទី៣ខាងក្រោមបង្ហាញយ៉ាងច្បាស់ថាចំណាយចរន្ត (ដែលប្រមាណមួយភាគបីគឺជាបៀវត្ស) ត្រូវបានចំណាយដូចដែលបានកំណត់នៅក្នុងច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ ដែលវាអាចបង្ហាញសុទិដ្ឋិនិយមថា នឹងមានការផ្តល់ជាក់ស្តែងនូវវិក្កយប័ត្រប្រាក់ឈ្នួលខ្ពស់ (ចំណាយចរន្ត) សំរាប់ក្រសួងសុខាភិបាល ក្រសួងអប់រំ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចបានបង្ហាញនៅក្នុងរូបភាពទី២ ។

ចំពោះចំណាយមូលធនរូបភាពនេះបង្ហាញថាក្រសួងទាំងអស់លើកលែងតែក្រសួងអប់រំ យុវជន និងកីឡាបានចំណាយតិចជាងថវិកាដែលបានកំណត់ក្នុងកំឡុងឆ្នាំ២០០៦ ។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍នូវព័ត៌មានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីហេតុផលសំរាប់ការចំណាយមិនគ្រប់គ្រាន់នេះ (និងការចំណាយលើសខ្ទង់នៅក្នុង ក្រសួងអប់រំ) ជារបាយការណ៍បែបពិពណ៌នាមួយស្តីពីការចំណាយទាំងនោះ ។គំរូនៃការចំណាយមិនអស់នៅក្នុងរូបភាពទី៣ គួរតែត្រូវបានចាត់ ទុកជាសញ្ញាប្រាប់ឱ្យដឹងជាមុនមួយថាការវិភាជន៍មូលធនដែលត្រូវបានបង្កើនសំរាប់ក្រសួងសុខាភិបាល ក្រសួងកសិកម្ម ក្រសួងរុក្ខាប្រមាញ់និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ មិនអាចត្រូវបានប្រែក្លាយឱ្យទៅជាចំណាយដែលកើនឡើងសំរាប់ក្រសួងទាំងនេះឡើយ ។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលសូមជំរុញ




*ប្រភព : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦*

ឱ្យក្រសួងសេដ្ឋកិច្ច និងក្រសួងពាក់ព័ន្ធទាំងបីនេះធ្វើការឈានទៅរកអត្រាបើកចំណាយឱ្យបានមួយភាគរយនៅក្នុងវិស័យអាទិភាពទាំងបីនេះ ។

## ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះគោលនយោបាយគាំទ្រជនក្រីក្រ

ការផ្តល់សិទ្ធជា "អាទិភាព" ឱ្យក្រសួង/ស្ថាប័នជាក់លាក់ណាមួយ ញ៉ាំងឱ្យមានការរំពឹងទុកថា ថវិការបស់ខ្លួនត្រូវបានផ្តល់នូវសារៈសំខាន់ជាងផ្នែក "ដែលមិនមែនជាអាទិភាព"។ ឧទាហរណ៍ វាជាការសមហេតុផលដែលត្រូវរំពឹងថាថវិការបស់ក្រសួង/ស្ថាប័ន "អាទិភាព" នឹងទទួលបាននូវអាទិភាពទី១ ប្រសិនបើមានលុយបន្ថែមសំរាប់ថវិកាជាតិ ។

តារាងទី១ខាងក្រោមផ្តល់នូវទិដ្ឋភាពទូទៅនៃក្រសួង/ស្ថាប័នលំដាប់ថ្នាក់លើគេចំនួនប្រាំដែលបានចំណាយលើសពីថវិកាដែលបានគ្រោងទុកនៅក្នុងច្បាប់ថវិកាជាតិសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ ទៅលើបៀវត្ស ការធ្វើដំណើរ សម្ភារៈបរិក្ខារការិយាល័យតូចតាច ។ល។ ដែលស្ថិតក្នុងប្រភេទនៃចំណាយចរន្ត។ តាមរយៈតារាងនេះបង្ហាញច្បាស់ថារដ្ឋាភិបាលគួរផ្តល់ការពន្យល់ពីមូលហេតុដែលក្រសួងចំណាយច្រើនលំដាប់ថ្នាក់លើសគេទាំងប្រាំនេះបានចំណាយអស់ជាង២៥ លានដុល្លារទៅលើប្រាក់បៀវត្ស ខណៈដែលលុយនេះគួរចំណាយទៅលើប្រាក់ខែគ្រូបង្រៀន បុគ្គលិកសុខាភិបាល អ្នកផ្សព្វផ្សាយកសិកម្មដែលត្រូវបានហៅជាផ្លូវការថាជា "អាទិភាព"។

**តារាងទី១ :** ក្រសួង/ស្ថាប័ន "មិនមែនអាទិភាព" ដែលធ្វើការចំណាយចរន្តលើសខ្ទង់លំដាប់ថ្នាក់លើគេទាំងប្រាំនៅក្នុងឆ្នាំ២០០៦

| ក្រសួង/ស្ថាប័ន | ភាគរយចំណាយរួម (គិតជាតួលេខមានតែនាម) | ជាលានរៀល (គិតជាតួលេខមានតែនាម) | ជាលានដុល្លារអាមេរិក (គិតជាតួលេខមានតែនាម) |
|---|---|---|---|
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ៣៣៩% | ២១.៨៣៨ | ៥.៣ |
| ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ | ១៩១% | ១៨.១០៤ | ៤.៤ |
| ទីស្តីការគណៈរដ្ឋមន្ត្រី | ១៧៣% | ៤៦.៤២២ | ១១.៣ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១៥៦% | ២១.៩២០ | ៥.៣ |
| លេខាធិការដ្ឋានមុខងារសាធារណៈ | ១៤៣% | ៦៥៩ | ០,២ |
| *សរុប* | | ១០៨.៩៤៣ | ២៦.៥ |

*ប្រភព : ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦, ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

តារាងទី២ បង្ហាញពីក្រសួង/ស្ថាប័ន "មិនមែនអាទិភាព" លំដាប់ថ្នាក់លើគេចំនួនប្រាំដែលបានចំណាយមូលធនលើសខ្ទង់កំឡុងឆ្នាំ២០០៦ ដែលជាការចំណាយលើអគារ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ឧបករណ៍ធំៗ ។ល។ តារាងនេះបង្ហាញឱ្យឃើញថា មានការចំណាយលើសខ្ទង់ដ៏គួរឱ្យកត់សំគាល់ (ជិត៦៥លានដុល្លាអាមេរិក) នៅក្នុងឆ្នាំ២០០៦ ខណៈដែលក្រសួងអាទិភាពជាទូទៅទទួលបានថវិកាតិចជាងការគ្រោងទុកលើកលែងតែក្រសួងអប់រំ ដូចដែលបានបង្ហាញនៅក្នុងតារាងទី៣។

**តារាងទី២:** ក្រសួង/ស្ថាប័ន "មិនមែនអាទិភាព" លំដាប់ថ្នាក់លើគេទាំងប្រាំមួយ ដែលចំណាយលើសខ្ទង់នៅក្នុងចំណាយមូលធន នៅក្នុងឆ្នាំ២០០៦

| ក្រសួង/ស្ថាប័ន | ភាគរយចំណាយរួម (គិតជាតួលេខសន្មត) | ជាលានដុល្លាអាមេរិក (គិតជាតួលេខសន្មត) |
|---|---|---|
| ក្រសួងបរិស្ថាន | ១១៤៥% | ១៥.០ |
| ក្រសួងមហាផ្ទៃ | ៤៥៨% | ១៤.៧ |
| ក្រសួងយុត្តិធម៌ | ៣៦៤% | ២.៦ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣១៨% | ៤.៣ |
| ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ | ២៤៦% | ៤.៣ |
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ២៤៤% | ២៣.៣ |
| *សរុប* | | ៦៤.២ |

*ប្រភព : ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦, ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧*

ការពិភាក្សាលើចំណាយនៅក្នុងក្រសួង "ដែលមិនមែនអាទិភាព" ខាងលើ បង្ហាញយ៉ាងច្បាស់ថា ការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះគោលនយោបាយគាំទ្រជនក្រីក្រគួរតែមានកំរិតខ្ពស់ជាងនេះ ពីព្រោះការចំណាយលើសផែនការដែលបានបង្ហាញឱ្យឃើញនៅក្នុងវិស័យ "ដែលមិនមែនអាទិភាព" (ប្រមាណ៩០ លានដុល្លារអាមេរិក) នឹងជួយរួមចំណែកខ្លាំងជាងពេលបច្ចុប្បន្នក្នុងការកាត់បន្ថយភាពក្រីក្រប្រសិនបើទឹកប្រាក់ទាំងនេះត្រូវបានចំណាយទៅលើវិស័យអាទិភាពពិតប្រាកដដូចជា វិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ សុខាភិបាល និងអប់រំ ។

## *សេចក្ដីសន្និដ្ឋាន*

ការវិភាគនៅក្នុងឯកសារនេះ គឺផ្អែកលើច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ និង២០០៧ និងព័ត៌មានដែលទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីការអនុវត្តន៍ថវិកាឆ្នាំ២០០៦ ។ ជាមួយគ្នានេះប្រភពទាំងនេះគ្រាន់តែផ្ដល់ព័ត៌មានតិចតួចប៉ុណ្ណោះអំពីការវិភាជន៍ថវិកា និងការចំណាយ ។ ការពិព័ណ៌នាដែលពន្យល់អំពីជំរើសរបស់រាជរដ្ឋាភិបាលកម្ពុជាលើថវិកានេះមិនមានទេ ។ ជាមួយនឹងព័ត៌មានដ៏តិចតួចនេះ វាជាការពិបាកក្នុងការវាយតម្លៃលើ "ភាពគាំទ្រជនក្រីក្រ" របស់ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ហើយយើងសូមស្នើឱ្យក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្ដល់ទិន្នន័យថែមទៀតអំពីការវិភាជន៍ និងការអនុវត្តន៍ថវិកា និងការពិពណ៌នាលំអិតដែលពន្យល់អំពីជំរើស និងអាទិភាពរបស់រដ្ឋាភិបាលសំរាប់ច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៨ ។

ទោះបីជាទិន្នន័យដែលមានស្រាប់ មានតិចតួចក៏ដោយ ក៏ការសង្កេតជាទូទៅមួយចំនួនលើច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ និងការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះការចំណាយដែលគាំទ្រជនក្រីក្រត្រូវបានធ្វើឡើងដែរ ។

ទី១ សហគមន៍អង្គការមិនមែនរដ្ឋាភិបាល សូមអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានខិតខំប្រឹងប្រែងក្នុងការបង្កើនការវិភាជន៍ថវិកានៅក្នុងឆ្នាំ២០០៧សំរាប់វិស័យអាទិភាពទាំងប្រាំពីរ ។ ការវិភាជន៍ដែលត្រូវ បានបង្កើននៅក្នុងច្បាប់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧មានន័យថាការការចំណាយមូលធននៅក្នុងវិស័យសុខាភិបាល អប់រំ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នឹងធ្វើអោយលេចចេញជាការវិនិយោគពិតប្រាកដថែមទៀតលើឧបករណ៍បរិក្ខារ ការសាងសង់ និងការជួស

ជុលកែលំអ នៅក្នុងវិស័យទាំងនេះនៅក្នុងឆ្នាំ២០០៧។ ការវិវឌ្ឍន៍មួយទៀតដែលបង្ហាញពីការអភិវឌ្ឍន៍ជាវិជ្ជមាននោះគឺការវិភាជន៍ដែលបានកើនឡើងលើសពីមធ្យមសំរាប់ចំណាយចរន្ត (ដូចជាប្រាក់ឈ្នួល) នៅក្នុងក្រសួងសុខាភិបាល និងក្រសួងអប់រំ។

ទី២ ខណៈដែលវិស័យអាទិភាពគេស្គាល់ (លើកលែងតែក្រសួងអប់រំ) បានចំណាយស្មើរតែស្មើមិនគ្រប់ចំនួន ដែលបានធ្វើវិភាជន៍នៅក្នុងច្បាប់ថវិកា ឬតិចជាងការវិភាជន៍ដ៏គួរឱ្យកត់សំគាល់នោះ ក្រសួងមិនមែនអាទិភាពមួយចំនួនបានចំណាយលើសខ្ទង់ជាង៩០ លានដុល្លារអាមេរិក ដោយរដ្ឋាភិបាលមិនបានបង្ហាញនូវយុត្តិកម្មណាមួយចំពោះបញ្ហានេះដល់សាធារណៈជនឡើយ។ អង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលផ្តល់ការពន្យល់បំភ្លឺចំពោះ ការចំណាយលើសខ្ទង់នៅក្នុងក្រសួង "ដែល មិនមែនអាទិភាព" ទាំងនេះ។

ទី៣ ចំពោះច្បាប់ថវិកាឆ្នាំ២០០៨ បច្ចុប្បន្ន យើងសំណូមពរឱ្យរាជរដ្ឋាភិបាលអនុវត្តថវិកាស្របតាមច្បាប់ថវិកា ហើយប្រសិនបើអាចរកបានមូលនិធិបន្ថែមទៀត យើងសូមជំរុញឱ្យរាជរដ្ឋាភិបាលកំណត់អាទិភាពលើអាទិភាពរបស់ខ្លួន និងបង្កើនចំណាយសំរាប់វិស័យសុខភិបាល អប់រំ កសិកម្ម និងអភិវឌ្ឍន៍ជនបទ។

***សំរាប់ព័ត៌មានបន្ថែម***

វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
លោក អ៊ូ ស៊ីវហួច មន្ត្រីគំរោងតាមដានថវិកា
ទូរស័ព្ទ : 023 - 214 429, Ext 107
អ៊ីមែល : sivhuoch@ngoforum.org.kh

***អក្សរកាត់***

BL : ច្បាប់ថវិកា
CDCF : វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា
MoAFF : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
MoEYS : ក្រសួងអប់រំ យុវជន និងកីឡា
MoH : ក្រសួងសុខាភិបាល
MoLVT : ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
MoPWT : ក្រសួងសាធារណៈការ និងដឹកជញ្ជូន
MoRD : ក្រសួងអភិវឌ្ឍន៍ជនបទ
MoWA : ក្រសួងកិច្ចការនារី
NEP : ភាពជាដៃគូផ្នែកអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល
NGO : អង្គការមិនមែនរដ្ឋាភិបាល
NGOF : វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
RGC : រាជរដ្ឋាភិបាលកម្ពុជា

## សូចនាករតាមដានរួមសំខាន់ៗមួយចំនួនរបស់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០០៧

ដើម្បីអនុវត្ត និងត្រួតពិនិត្យតាមកាលបរិច្ឆេទកំណត់រវាងកិច្ចប្រជុំនៃវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ និងលើកទី២

តារាងខាងក្រោមនេះគឺជាសូចនាករតាមដានរួមឆ្នាំ២០០៧ដែលពាក់ព័ន្ធទៅនឹងការព្រួយបារម្ភ និងបញ្ហាអាទិភាពដែលសហគមន៍អង្គការមិនមែនរដ្ឋាភិបាលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលចំពោះវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០០៧។

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| **អាទិភាពក្នុងវិស័យសេដ្ឋកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ៧- អនុវត្ត និងត្រួតពិនិត្យភាពជាដៃគូក្នុងការអនុវត្តន៍បណ្តាអាទិភាពនៃវិស័យកសិកម្ម និងទឹក | ១- អនុវត្តជំហាន៧ នូវយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ :<br>ក- សម្រេចកិច្ចព្រមព្រៀងស្តីពីគោលការណ៍ សម្រាប់ណែនាំដៃគូអភិវឌ្ឍន៍ និងក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលបំពេញការងារក្នុងវិស័យកសិកម្ម និងទឹក នាចុងខែមិថុនា ឆ្នាំ២០០៧<br>ខ- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងដៃគូអភិវឌ្ឍន៍ អនុមតិក្របខ័ណ្ឌយោងសម្រាប់រៀបចំកម្មវិធី ទាំង៥នៃយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក នាខែកក្កដា ឆ្នាំ២០០៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យកសិកម្ម និងទឹក | | |
| | គ- រៀបចំបញ្ចប់កម្មវិធីជាតិចំនួន២ នាចុងខែធ្នូ ឆ្នាំ២០០៧ និង | | | | |
| | ឃ- រៀបចំបញ្ចប់កម្មវិធីជាតិចំនួន៥ នាចុងខែមិថុនា ឆ្នាំ២០០៨ | | | | |
| | ២- កែលំអការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយ :<br>ក- ភាគីពាក់ព័ន្ធទទួលបានព័ត៌មានស្តីពីសកម្មភាពទាំងអស់ តាមរយៈការធ្វើបច្ចុប្បន្នភាពព័ត៌មាន២ដងក្នុងមួយឆ្នាំ (ចុងខែមិថុនា និងចុងខែធ្នូ) នៅលើគេហទំព័ររបស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យកសិកម្ម និងទឹក។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យកសិកម្ម និងទឹក | | |
| ៨- អនុវត្តបទដ្ឋានគតិយុត្តិទាំងឡាយនៃច្បាប់ភូមិបាល | ១- អនុមតិគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច និងចាត់វិធានការការពារបឋម (ការបញ្ចប់ពីអត្តសញ្ញាណដី ការធ្វើផែនទីដីធ្លី រៀបចំចំណាត់ថ្នាក់ដី និងការអនុញ្ញាតិ បណ្តោះអាសន្នលើដី ដែលជនជាតិដើមភាគតិចបានទាមទារតាមច្បាប់) ដើម្បីការពារដីរបស់សហគមន៍ជនជាតិដើមភាគតិចទាំងនេះ នៅខេត្តចំនួន២ ក្នុងក្របខ័ណ្ឌរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងក្រុមការងារស្រុក ដូចមានចែងក្នុងអនុក្រិត្យលេខ ១១៨ ។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យកសិកម្ម និងទឹក | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| | ២- លើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជនក្រីក្រតាមជនបទ ។ប្រជាជនចំនួន ៥០០គ្រួសារអាចតាំងទីលំនៅលើដីសម្បទានសង្គមកិច្ច ដោយមានការគាំទ្រខាងជីវភាពរស់នៅ និងយ៉ាងតិច មានដីចំនួន១០.០០០ហ.ត ទៀត ត្រូវបានរក្សាសម្រាប់សម្បទានសង្គមកិច្ច ។ | | | | |
| ៩- ដើម្បីចៀសវាងការបាត់បង់ធនធានព្រៃឈើនៅកម្ពុជា ត្រូវអនុវត្តឱ្យបានពេញលេញ នៅតាមគ្រប់លំដាប់ថ្នាក់រដ្ឋបាល នូវក្របខ័ណ្ឌគតិយុត្តិទាំងឡាយស្របតាមច្បាប់ស្តីពីការគ្រប់គ្រងព្រៃឈើពិសេសការអនុវត្តន៍អនុក្រឹត្យស្តីពី ដីសម្បទានសេដ្ឋកិច្ច | ១- អនុវត្តអនុក្រឹក្យស្តីពីដីសម្បទានសេដ្ឋកិច្ច និងរៀបចំសៀវភៅកត់ត្រាអំពីដីសម្បទានសេដ្ឋកិច្ច សម្រាប់ផ្សព្វផ្សាយជាសាធារណៈរួមទាំង :<br>- ការសម្រេចរបស់ខេត្តក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច<br>- ពិនិត្យឡើងវិញការផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលមានទំហំច្រើនជាង ១០.០០០ហត ចំនួនយ៉ាងតិច ៥កន្លែង<br>- ចាត់វិធានការសមស្រប ដោយអនុលោមតាមជំពូកទី៦ នៃអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសសម្រុះសម្រាប់ការងារដីធ្លី និងក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារព្រៃ ឈើ និងបរិស្ថាន | | |
| | ២- អនុវត្តឱ្យបានឆាប់ និងទូលំទូលាយទូទាំងប្រទេស នូវការកំណត់ព្រំដែនដីព្រៃឈើ ស្របតាមអនុក្រឹត្យលេខ៥៣ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសសម្រុះសម្រាប់ការងារដីធ្លី និងក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារព្រៃ ឈើ និងបរិស្ថាន | | |
| ១០-ចាត់វិធានការសមស្រប ដើម្បីឆ្លុះបញ្ចាំងពីអាទិភាពនៃវិស័យជលផលសម្រាប់លើកកំរិតជីវភាពរស់នៅរបស់សហគមន៍ជនបទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ស្រុក ខេត្ត ដោយបញ្ជាក់អំពីកំរិតនៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ | ១- ពង្រាងបញ្ចប់នូវក្រមប្រតិបត្តិសម្រាប់ការងារជលផល នាចុងឆ្នាំ ២០០៧ ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសសម្រុះសម្រាប់ការងារ ជលផល | | |
| | ២- ពិភាក្សាជាមួយ និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាឱ្យរដ្ឋាភិបាលជលផលមានហិរញ្ញប្បទានគ្រប់គ្រាន់ (គិតទាំងចំណូលដែលបាន មកពីវិស័យនេះ) សម្រាប់អនុវត្តកាតព្វកិច្ចរបស់ខ្លួន ស្របតាមមាត្រាទី១៤ នៃច្បាប់ជលផល ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសសម្រុះសម្រាប់ការងារ ជលផល | | |
| | ៣- ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធផែនការ គណនេយ្យ និងត្រួតពិនិត្យរបស់រដ្ឋបាលជនផល ស្របតាមក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងប្រព័ន្ធប្រាក់បៀវត្សស្របតាមប្រសិទ្ធភាពការងារ នាចុងឆ្នាំ២០០៧។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសសម្រុះសម្រាប់ការងារ ជលផល | | |
| **អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| ១៤- បង្កើនការប្រើប្រាស់អនាម័យ និងទឹកស្អាត ពិសេសនៅតំបន់ជនបទ | ១-រៀបចំ និងអនុវត្តសាស្ត្រស្តីពីការផ្គត់ផ្គង់ទឹកនៅជនបទ និងអនាម័យព្រមទាំងថវិកា ដែលផ្អែកលើគោលនយោបាយស្តីពីការផ្គត់ផ្គង់ទឹកនៅជនបទ និងអនាម័យ ដោយត្រូវតម្រឹមជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ | ក្រសួងអភិវឌ្ឍន៍ជនបទ | បង្កើតអនុក្រុមការងារ ចំណុះក្រោមក្រុមការងារសមស្របណាមួយ | | |
| **អាទិភាពក្នុងវិស័យអភិបាលកិច្ច និងពហុវិស័យនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ១៥- បន្តពង្រឹងរដ្ឋបាលសាធារណៈ នឹងក្លាយជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ | ១- អនុវត្តយុទ្ធសាស្ត្ររួមរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ស្តីពីការឈប់អនុវត្តជាជំហាន១ នូវការផ្តល់ប្រាក់បៀវត្សបន្ថែមដោយ :<br>ក- អនុវត្តផែនការសកម្មភាពតាមវិស័យដែលបានឯកភាព និង<br>ខ- បង្កើតកន្សោមអាទិភាព និងអនុវត្តប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមប្រសិទ្ធភាពការងារ នៅក្រសួងសុខាភិបាល និងយ៉ាងតិចបំផុតនៅក្រសួង/ស្ថាប័នមួតទៀត | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងក្រសួងពាក់ព័ន្ធ | ក្រុមការងារស្តីពីកំណែទំរង់រដ្ឋបាល និង ក្រសួងពាក់ព័ន្ធ | | |
| | ២- កែលំអការផ្តល់ប្រាក់បៀវត្សរ៍ និងលក្ខខ័ណ្ឌការងាររបស់មន្ត្រីរាជការ:<br>ក- រៀបចំយុទ្ធសាស្ត្រ និងផែនការរយៈពេលមធ្យមសម្រាប់កែលំបៀវត្សរ៍<br>ខ- រៀបចំគោលនយោបាយ និងផែនការសកម្មភាពស្តីពីការពង្រាយមន្ត្រីរាជការ | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | ក្រុមការងារពីកំណែទំរង់រដ្ឋបាល | | |
| | ៣- រៀបចំ និងអនុវត្តគោលនយោបាយ និងផែនការសកម្មភាពស្តីពីការគ្រប់គ្រងធនធានមនុស្ស ដោយប្រើប្រាស់មគ្គុទេសក៏ស្តីពីការគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងព័តិមានធនធានមនុស្ស សម្រាប់មន្ត្រីរាជការស៊ីវិល | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងក្រសួងពាក់ព័ន្ធ | ក្រុមការងារកំណែទំរង់រដ្ឋបាល និង ក្រសួងពាក់ព័ន្ធ | | |
| | ៤- កែលំអការផ្តល់សេវា តាមរយៈការបង្កើតយន្តការបញ្ជរតែមួយ និងពង្រឹងក្របខ័ណ្ឌច្បាប់ ដោយបង្កើតបញ្ជរតែមួយ យ៉ាងតិចបំផុត៥កន្លែងទៀតនៅទូទាំងប្រទេស | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | ក្រុមការងារពីកំណែទំរង់រដ្ឋបាល | | |
| ១៦- រៀបចំប្រព័ន្ធច្បាប់ និងតុលាការឱ្យដំណើរការល្អ ប្រកបដោយគណនេយ្យភាព និងតម្លាភាពដែលការពារសិទ្ធិបុគ្គល ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ | ១- គោលដៅទី២ នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ : បញ្ចប់ការរៀបចំសេចក្តីព្រាងច្បាប់ និងអនុមតិច្បាប់សំខាន់ៗដែលនៅសេសសល់ (ក្រមស្តីពីនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទ័ណ្ឌ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ និងច្បាប់ស្តីពីការធ្វើវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម)។ | ក្រសួងយុត្តិធមិ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទំរង់ច្បាប់ និងតុលាការ | | |
| | ២- គោលដៅទី២ និង៧នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ : រៀបចំបញ្ចប់ នូវគោលការណ៏ណែនាំសម្រាប់ដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ដោយផ្អែកលើបទពិសោធន៏កន្លងមក។ គោលការណ៏ណែនាំនេះនឹងលើក | ក្រសួងយុត្តិធមិ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទំរង់ច្បាប់ និងតុលាការ | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| | អំពីតម្រូវការខាងកិច្ចសហប្រតិបត្តិការបច្ចេកទេស សម្រាប់កសាងសមត្ថភាព និងសម្រាប់ពង្រឹងភាពម្ចាស់របស់អង្គភាពរៀបចំច្បាប់នៃក្រសួងពាក់ព័ន្ធ។ | | | | |
| | ៣- គោលដៅទី៤និង៧ នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ : ការបណ្តុះបណ្តាល និងការជ្រើសរើសប្រកបដោយតម្លាភាពនូវមន្ត្រីបំរើឱ្យផ្នែកតុលាការនិងច្បាប់ដើម្បីកែលំអការផ្តល់សេវាតុលាការ និងកិច្ចដំណើរការរបស់តុលាការ។ | ក្រសួងយុត្តិធម៌ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទំរង់ច្បាប់ និងតុលាការ | | |
| ១៧- ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ | ១- រៀបចំបញ្ចប់ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ស្របតាមបទដ្ឋានជាអន្តរជាតិ។ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងទីស្តីការគណៈរដ្ឋមន្ត្រី | ក្រុមការងារកំណែទំរង់ច្បាប់ និងតុលាការ | | |
| | ២- រៀបចំផែនការសម្រាប់គ្រប់គ្រងការអនុវត្តន៍ច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ។ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងទីស្តីការគណៈរដ្ឋមន្ត្រី | ក្រុមការងារកំណែទំរង់ច្បាប់ និងតុលាការ | | |
| | ៣- ផ្សព្វផ្សាយជាទៀងទាត់ ៦ខែម្តងព័ត៌មានស្តីពីករណីអំពើពុករលួយ និងការផ្តន្ទាទោស។ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកច្ច និងទីស្តីការគណៈរដ្ឋមន្ត្រី | ក្រុមការងាកំណែទំរងច្បាប់ និងតុលាការ | | |
| | ៤- រៀបចំក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ។ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកច្ច និងទីស្តីការគណៈរដ្ឋមន្ត្រី | ក្រុមការងាកំណែទំរងច្បាប់ និងតុលាការ | | |
| ១៨- រៀបចំសម្រាប់អនុវត្តឱ្យបានពេញលេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិស្តីពីកំណែទំរង់ វិមជ្ឈការ និងវិសហមជ្ឈការ | ១- បន្តរៀបចំសេចក្តីព្រាងច្បាប់អង្គការស្តីពីកិច្ចអភិវឌ្ឍន៍មូលដ្ឋាននៅក្រោមថ្នាក់ជាតិ និង ផ្តួចផ្តើមការពិគ្រោះយោបល់ទូលាយ ជាមួយភាគីពាក់ព័ន្ធ (ត្រីមាសទី ៤ ឆ្នាំ ២០០៧ និងឆ្នាំ២០០៨) ។ | គណៈកម្មាធិការដឹកនាំការងារកំណែទំរង់ វិមជ្ឈការ និង វិសហមជ្ឈការ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិមជ្ឈការ និង វិសហមជ្ឈការ | | |
| | ២- រៀបចំកម្មវិធីជាតិ ដោយបញ្ជាក់ពីទំរង់ការ និងធនធានសម្រាប់អនុវត្ត ។ (ត្រីមាសទី ៣ ឆ្នាំ ២០០៧ ដល់ត្រីមាសទី២ ឆ្នាំ២០០៨) ។ | គណៈកម្មាធិការដឹកនាំការងារកំណែទំរង់ វិមជ្ឈការ និង | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិមជ្ឈការ និង វិសហមជ្ឈការ | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| | | វិសហមជ្ឈការ | | | |
| | ៣- រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍រៀបចំគោលការណ៍នៃការចូលរួម សម្រាប់គាំទ្រកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ( ត្រីមាសទី៣ និងទី៤ ឆ្នាំ២០០៧) | គណៈកម្មាធិការដឹកនាំការងារកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិមជ្ឈការ និង វិសហមជ្ឈការ | | |
| ១៩- បង្កើនជំនឿទុកចិត្តលើថវិការរដ្ឋ និងបង្កើនគណនេយ្យភាពក្នុងកិច្ចការហិរញ្ញវត្ថុ | ១- បន្តអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយ<br>ក- រក្សាឱ្យបាននូវសមិទ្ធផលដែលបានសម្រេចកន្លងមក និង អនុវត្តបញ្ចប់នូវបណ្តាសកម្មភាព ដែលនៅសេសសល់ក្នុងដំណាក់កាលទី១<br>ខ- រៀបចំផែនការសកម្មភាពសម្រាប់ជំហានទី២នៃដំណាក់កាលទី២រួមទាំងផ្តល់អនុសាសន៍សម្រាប់ជាមូលដ្ឋានក្នុងការអនុមតិគំនិតផ្តួចផ្តើមស្តីពីតម្លាភាពក្នុងវិស័យឧស្សាហកម្មរុករក<br>គ- បន្តត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករដែលបានឯកភាពក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | |
| **អាទិភាពក្នុងវិស័យសង្គមកិច្ចនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** | | | | | |
| ៣- កែលំអកាលានុវត្តភាពសម្រាប់ការសិក្សានៅកំរិតបឋមភូមិ | ១- បង្កើនអត្រាចុះឈ្មោះចូលរៀននៅកំរិតបឋមភូមិ( សរុប និងតាមភេទ) ។<br>២- បង្កើនអត្រាឡើងថ្នាក់ ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ ។ | ក្រសួងអប់រំ យុវជន និងកីឡា | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យអប់រំ | | |
| ៤- បង្កើនចំនួនស្រ្តីសម្រាលបុត្រដោយឆ្មប់ជំនាញឱ្យបាន ៤៥% នៅខែធ្នូ ឆ្នាំ២០០៧ ( ៣៨% ក្នុងឆ្នាំ២០០៦) | ១- ជ្រើសរើសឆ្មបយ៉ាងតិចចំនួន ៦៨នាក់ឱ្យបាននៅចុងឆ្នាំ២០០៧ សម្រាប់មណ្ឌលសុខភាពចំនួន៦៨ ដែលបច្ចុប្បន្ននេះ មិនទាន់មានឆ្មប ។ | ក្រសួងអប់រំសុខាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិសយ័សុខាភិបាល | | |
| | ២- ផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មប ។ ប្រាក់ឧបត្ថមត្រូវផ្តល់តាមចំនួនសេវាដែលបានកំនត់ក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល លេខ២៦៨ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៧ និង កាំប្រាក់បៀវត្សរ៍របស់ឆ្មប និង ប្រាក់ឧបត្ថមបន្ថែមសម្រាប់ហានិភ័យ ក្នុងវិជ្ជាជីវៈ ដែលបានរៀបចំដោយសុខាភិបាល សម្រាប់ស្នើជូនគណៈរដ្ឋមន្ត្រី ពិនិត្យនិងសម្រេច ។ | ក្រសួងអប់រំសុខាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិសយ័សុខាភិបាល | | |
| ៦- សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងត្រូវឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្រ្តតាមវិស័យ | ១- ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងរៀបចំក្របខ័ណ្ឌយុទ្ធសាស្រ្តសម្រាប់បញ្ជ្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់ស្នើជូនក្រសួងពាក់ព័ន្ធពិភាក្សា និងសម្រេច | ក្រសួងផែនការ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងអភិវឌ្ឍន៍ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សន្តិសុខស្បៀង និង អាហារូបត្ថម្ភ | | |

* លោកអ្នកអាចទំនាក់ទំនងរតារាងដែលមានសូចនាករតាមដានរួមទាំងអស់បានពីលោក ង៉ោ សុថាត នៃគំរោងគោលនយោបាយអភិវឌ្ឍន៍របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា តាមរយៈអ៊ីម៉ែល sothath@ngoforum.org.kh ។

** លោកអ្នកអាចរកមើលឯកសារនេះបាននៅលើគេហទំព័ររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាតាមរយៈ http://www.ngoforum.org.kh/Development/Docs/doc.htm.